# ប្រទេសកម្ពុជា និងសាមគ្គីភាពសង្គម ៖
# ការសិក្សាក្នុងបរិបទបច្ចុប្បន្ន



# មាតិកា


១-សេចក្តីផ្តើម……………………………………………………………………………………. 3

២-សាមគ្គីភាពសង្គមៈ កម្ពុជា និងការយល់ឃើញ ………………………………………………. 7

៣-ការយល់ឃើញរបស់**ពលរដ្ឋកម្ពុជាៈ វិមាត្រនៃ**សាមគ្គីភាពសង្គម ……………................. 14

វិមាត្រ ១ៈ ការជឿទុកចិត្ត ………………………………………………………………. 14

វិមាត្រ ២ៈភាពចូលចំណោម…………………………………………………………………. 18

វិមាត្រ ៣ៈ ភាពបរិយាបន្ន ………………………………………………………………….. 22

វិមាត្រ ៤ៈ សន្តិសុខ………………………………………………………………………….. 27

៤-សង្ខេប………………………………………………………………………………….. 30

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ។ កំណើនសេដ្ឋកិច្ចជាមធ្យមគឺ៧,៧% ចន្លោះពីឆ្នាំ១៩៩៨ និងឆ្នាំ២០១៩[1]។ ការណ៍នេះបានផ្លាស់ប្តូរប្រទេសដែលមានប្រជាពលរដ្ឋជាង១៦លាននាក់ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។

បើទោះជាមានការធ្លាក់ចុះសេដ្ឋកិច្ច៣,១%នៅឆ្នាំ២០២០ ដោយសារជំងឺដែលបង្កដោយមេរោគកូវីដ សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើន៤%នៅឆ្នាំ២០២១ និងកើនបាន ៥,៥%នៅឆ្នាំបន្ទាប់។ នេះបើ យោងតាមរបាយការណ៍ថ្មីៗ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)[2]។ វឌ្ឍនភាពនៃប្រទេសអាស៊ីអាគ្នេយ៍មួយនេះ មិនមែនមានត្រឹមតែអត្រាកំណើនសេដ្ឋកិច្ចនោះទេ។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា (HDI) ស្ថិតក្នុងកម្រិត ០,៥៩៤ នៅឆ្នាំ២០១៩ គឺកើនបាន ៦១,៥% គិតចាប់តាំងពីឆ្នាំ១៩៩០ មក។ HDI បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជា ជាប្រភេទប្រទេសដែលមានការអភិវឌ្ឍន៍ធនធានមនុស្សកម្រិតមធ្យម ដោយស្ថិតក្នុងលេខរៀងទី១៤៤ ក្នុងចំណោមប្រទេសនិងដែនដីសរុបចំនួន ១៨៩[3]។ ដោយសារកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ ទើបធ្វើឲ្យប្រទេសកម្ពុជាមានវឌ្ឍនភាពទៅលើផ្នែកផ្តល់សេវាកម្មសង្គម ហើយនិងភាពប្រសើរឡើងទៅលើផ្នែក ធនធានមនុស្ស សង្គម និងរូបវន្ត ដែលកត្តាចាំបាច់សម្រាប់ទំនើបកម្ម។ កត្តានេះបាននាំឱ្យយុវជនកម្ពុជានាពេលបច្ចុប្បន្ន[4] ជាពិសេសយុវជននៅតាមទីក្រុង ទទួលបានបទពិសោធន៍ផ្សេងៗពីហេដ្ឋារចនាសម្ពន្ធ័ជុំវិញ វប្បធម៌ និងការអភិវឌ្ឍពីជំនាន់មុន។ ប្រការនេះផ្តល់ជាទុនដល់ការបង្កើតទស្សនៈក្នុងពិភពដែលខុសប្លែកពីជំនាន់មុនៗ រួមទាំងជំនាន់ឪពុកម្តាយនិងជីដូនជីតាពួកគេផងដែរ។

ក្រៅពីបទពិសោធន៍នៃការវិវត្តសក្តានុពលសង្គម និងសេដ្ឋកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមយុវជនមានលក្ខណៈពិសេសដាច់ដោយឡែក នោះគឺពួកគេជាប្រជាជនភាគច្រើនក្នុងប្រទេស។ បច្ចុប្បន្នប្រមាណ២ភាគ៣ នៃប្រជាជនកម្ពុជាមានអាយុក្រោម៣០ឆ្នាំ[5]។ គំនូសតាងទី១ បង្ហាញពីភាពខុសគ្នានៃជំនាន់មនុស្សក្នុងទម្រង់ពីរ៉ាមីតតាមលំដាប់អាយុ។

បើធៀបទៅនឹងជំនាន់មុនពួកគេ យុវជនដែលមានអាយុក្រោម៣០ឆ្នាំ ទទួលព័ត៌មានកាន់តែច្រើន និងចូលរួមកាន់តែច្រើនក្នុងលំហប្រជាជនដោយសារការជ្រៀតចូលយ៉ាងឆាប់រហ័សនៃប្រព័ន្ធអ៊ីនធើណែត ជាពិសេសប្រព័ន្ធផ្សព្វផ្សាយសង្គម[6]។

**គំនូសតាងទី១៖ ពីរ៉ាមីតស្តីពីពលរដ្ឋកម្ពុជា(%)[7]**

[1] The World Bank In Cambodia. (2021). Retrieved 8 November 2021, from https://www.worldbank.org/en/country/cambodia/overview#1

[2] Cambodia's Economy to Recover in 2021, Accelerate in 2022 — ADB. (2021). Retrieved 13 November 2021, from https://www.adb.org/news/cambodia-economy-recover-2021-accelerate-2022-adb

[3] The Next Frontier: Human Development and the Anthropocene. (2020). Retrieved 19 November 2021, from http://hdr.undp.org/sites/default/files/Country-Profiles/KHM.pdf

[4] Cambodian youth are referred to as people of both sexes aging between 15 and 30 years and with Cambodian nationality regardless of their marital status. (MOEYS, National Policy on Development of Cambodian Youth, 2011)

[5] Cambodia Youth Data Sheet 2015. (2016). Retrieved 14 November 2021, from https://cambodia.unfpa.org/sites/default/files/pub-pdf/Flyer_Cambodia_Youth_Factsheet_final_draft_%28approved%29.pdf

[6] Bong, C., & Sen, C. (2017). Research Brief: Youth Political Participation in Cambodia. Politikoffee and Konrad Adenauer Stiftung Cambodia. Retrieved from https://www.kas.de/c/document_library/get_file?uuid=b71a2520-4428-56c4-c937-b56948c9bde0&groupId=252038

[7] World Population Review (2022). Retrieved from https://worldpopulationreview.com/countries/cambodia-population




យ៉ាងណាក្តី វឌ្ឍនភាពសេដ្ឋកិច្ចរបស់កម្ពុជាកើតមានឡើងទន្ទឹមគ្នានឹងការបង់ខាតមួយចំនួន ដែលប្រទេសមួយចំនួនដែលមានស្ថានភាពប្រហាក់ប្រហែល បានជួបប្រទះកន្លងមក ជាពិសេសនៅក្នុងនោះ វិសមភាពក្នុងការចែករំលែកចំណូល និងធនធាន បានស្តែងកាន់តែច្បាស់ក្រឡែតឡើងៗ។ ថ្វីត្បិតតែការចល័តទី និងឱកាសសេដ្ឋកិច្ចកាន់តែមានភាពសម្បូរបែបជាងមុនមែន ប៉ុន្តែក្រុមជនងាយរងគ្រោះនៅក្នុងសង្គម រួមមាន ជនជាតិដើមភាគតិច ស្ត្រី ពលរដ្ឋមានពិការភាព និងក្រុមអ្នកស្រលាញ់ភេទដូចគ្នា (LGBTQI+) នៅតែបន្តប្រឈមនឹងបញ្ហាច្រើន ដែលរារាំងដល់ការចល័តទីផ្នែកសេដ្ឋកិច្ច ការទទួលបានសន្តិសុខ និងឱកាសនានា នៅក្នុងសង្គម[៨]។

អាស្រ័យហេតុនេះ ហើយជាសារសំខាន់នៅក្នុងក្របខណ្ឌពេលវេលានៃការតាក់តែងរបាយការណ៍នេះឡើង ចាំ បាច់ត្រូវរៀបចំឱ្យមានការស្វែងយល់បានល្អអំពីសាមគ្គីភាពសង្គម ដើម្បីចូលរួមឆ្លើយតបទៅនឹងផលប៉ះពាល់ពី ជំងឺកូវីដ-១៩ កន្លងមក។

ក្នុងអំឡុងពេលនៃជំងឺឆ្លងនេះ ជោគជ័យរបស់ប្រទេសកម្ពុជាបានមកពីវិធានការទាក់ទងនឹងការត្រួតពិនិត្យព្រំ ដែន និងវិធានការបង្ការ (ដូចជាការបិទសាលារៀន និងយុទ្ធនាការចាក់វ៉ាក់សាំងនៅទូទាំងប្រទេស)។ ទោះជាទទួលបានជោគជ័យផ្នែកសុខាភិបាល ព្រះរាជាណាចក្រកម្ពុជាជានិច្ចកាលប្រឈមនឹងការលំបាកមួយចំនួន ដូចជា វិស័យក្រៅផ្លូវការ កសិករ សហគ្រាសធុនតូចនិងមធ្យម បន្តប្រឈមជុំវិញប្រាក់ចំណូលនិងផលិតភាពដែលបណ្តាលមកពីវិធានការបង្កានៅក្នុង

[8] Cambodia Development Resource Institute (CDRI). (2020). Gender & Inclusive Development Analysis. USAID Cambodia. Retrieved from https://pdf.usaid.gov/pdf_docs/PA00X7PN.pdf

ប្រទេសកម្ពុជា និងនៅក្រៅប្រទេស។ ផលប៉ះពាល់មិនមែនមានតែនៅលើផ្នែកសុខភាពទេ ប៉ុន្តែបានប៉ះដល់ការពិតផ្នែកសង្គមនិងសេដ្ឋកិច្ច ដែលទាមទារឱ្យមានដំណោះស្រាយសម្រាប់រយៈពេលយូរ។

ខណៈដែលព្រះរាជាណាចក្រកម្ពុជាពន្លឿនការអភិវឌ្ឍរបស់ខ្លួនជាមួយនឹងក្រុមយុវជន កម្ពុជាបន្តឃ្លាតឆ្ងាយពីអតីតកាលដ៏ខ្មៅងងឹតនៃសម័យខ្មែរក្រហម។ ទោះជាទទួលបានជំហានវិជ្ជមានបែបនេះក៏ដោយ រឿងនិទានប្រវត្តិសាស្ត្រមួយចំនួននៅតែរាលដាលគ្រប់ទីកន្លែង។ ក្នុងការប្រឹងប្រែងរបស់ខ្លួនដើម្បីរក្សាសន្តិភាព និទានកថាស្តីពី ***សន្តិភាពតាមរយៈការឯកភាពជាតិ*** នៅតែត្រូវបានគេប្រើប្រាស់ជាបន្តទៀត។
យើងត្រូវមានការផ្តោតជាថ្មីជុំវិញគោលគំនិតស្តីពីសន្តិភាពតាមរយៈការប្រើប្រាស់បរិបទនៃសាមគ្គីភាពសង្គម- ការបញ្ចូល និងធាតុផ្សំ ហើយនិងវិមាត្រពាក់ព័ន្ធរបស់វា។

ដូច្នេះ របាយការណ៍នេះបន្តស្វែងយល់ពីគោលគំនិតនៃសាមគ្គីភាពសង្គម និង ស្នើឱ្យមានការយល់ឃើញ ពាក់ព័ន្ធក្នុងបរិបទបច្ចុប្បន្នរបស់ប្រទេសកម្ពុជា។

**កំណត់ចំណាំលើវិធីសាស្ត្រ (Methodological Approach)**

មុននឹងស្វែងយល់ពីនិយមន័យនិងការវាស់ស្ទង់នៃសូចនាករនៃសាមគ្គីភាពសង្គម វាមានសារសំខាន់ក្នុងការនិយាយអំពីវិធីសាស្ត្រនៃការរៀបរៀងក្នុងរបាយការណ៍នេះ។

របាយការណ៍នេះ ត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវចំនួនបី ដែលត្រូវបានប្រើប្រាស់នៅក្នុងផ្នែកផ្សេងៗគ្នារបស់របាយការណ៍ និងការធ្វើតារាងគំរូ៖

១. **ការពិនិត្យឯកសារ៖** ដំណើរការនៃការកំណត់អត្តសញ្ញាណនិងការពិនិត្យឯកសារគោលគំនិតពាក់ព័ន្ធដើម្បីបង្កើតគំនិតស្តីពីសាមគ្គីភាពសង្គម ដែលសមស្របហើយនិងអាចអនុវត្តបាននៅប្រទេសកម្ពុជា។
The process of identifying and examining relevant conceptual materials to build a concept of Social Cohesion that is relevant and applicable to Cambodia.
២. **ក្រុមអ្នកជំនាញ និងការពិនិត្យវាយតម្លៃ៖** ការបង្ហាញពីកំណត់ត្រានៃគំនិត ដើម្បីទទួលយកមតិពីថ្នាក់ដឹកនាំសង្គមស៊ីវិល និងអង្គការអន្តរជាតិ។ មតិយោបល់របស់ពួកគេត្រូវបានដាក់បញ្ចូលក្នុងសូចនាករ និងប្រភពដែលត្រូវបានស្នើឡើងក្នុងវិធីសាស្ត្រ។
៣. **ការស្វែងយល់បន្ថែមអំពីប្រធានបទសាមគ្គីភាពសង្គមតាមរយៈការសរសេរអត្ថបទអត្ថាធិប្បាយ៖** - ការផលិតអត្ថបទអត្ថាធិប្បាយគោលនយោបាយសាធារណៈចំនួន៣០ ជាខេមរៈភាសា និងជាភាសាអង់គ្លេសដោយស្វែងយល់អំពីគោលគំនិតនៃសាមគ្គីភាពសង្គមតាមប្រធានបទ។ គុណតម្លៃនៃសកម្មភាពនេះត្រូវបង្កើតសហគមន៍ដែលចាប់អារម្មណ៍លើគំនិត និងបញ្ចូលចំណុចសំខាន់ៗទៅក្នុងរបាយការណ៍និងគំរូ។

## ២. សាមគ្គីភាពសង្គម៖ ព្រះរាជាណាចក្រកម្ពុជា និងគោលគំនិត

សាមគ្គីភាពសង្គម មិនមែនជាគំនិតថ្មីនោះទេ ប៉ុន្តែវាពិតជាមានលក្ខណៈបត់បែន។ ទោះជាសាមគ្គីភាពសង្គមទទួលបានប្រជាប្រិយភាពក្នុងចំណោមសហគមន៍អ្នកសិក្សានិងអ្នកបង្កើតគោលនយោបាយក៏ដោយ ក៏និយមន័យជាក់លាក់នៃសាមគ្គីភាពសង្គមនៅតែមិនច្បាស់លាស់ ហើយវាអាស្រ័យទៅតាមបរិបទ[9]។ និយមន័យរបស់គោលគំនិតមួយនេះ មានភាពខុសគ្នាទៅតាមអ្នកនិពន្ធ

[9] Chan, J., To, H., & Chan, E. (2006). Reconsidering Social Cohesion: Developing a Definition and Analytical Framework for Empirical Research. *Social Indicators Research*, *75*(2), 273-302. doi: 10.1007/s11205-005-2118-1; Croissant, A., & Walkenhorst, P. (2021). Social Cohesion in Asia: Historical Origins, Contemporary Shapes and Future Dynamics (pp. 1-25). Oxon: Routledge.

ម្នាក់ៗ ដែលជារឿយៗនាំឲ្យមានការកំណត់និយមន័យដោយផ្តោតទៅលើអវិជ្ជមាននៃគំនិតមួយនេះ ជាជាងការព្យាយាមកំណត់ទៅតាមលក្ខណៈវិនិច្ឆ័យដែលមានស្រាប់។

បើទោះជាខ្វះនិយមន័យច្បាស់លាស់និងឯកភាពគ្នាក៏ដោយ ក៏ចំណុចស្នូលនៃសាមគ្គីភាពសង្គមចាប់ផ្តើមដោយការស្វែងយល់ពីគោលគំនិតនៃសាមគ្គីភាព និងការជឿទុកចិត្តគ្នា។ ជាបន្តបន្ទាប់ និងផ្អែកតាមវត្ថុបំណងគោលគំនិត ចំណុចស្នូលត្រូវបានពង្រីកដើម្បីបញ្ចូលវិមាត្រផ្សេងទៀតដូចជាបរិយាបន្ន មូលធនសង្គម និងភាពក្រីក្រ[10]។

មិនថាទិដ្ឋភាពដទៃទៀតត្រូវបានបញ្ចូលឬអត់នោះទេ លក្ខណៈសណ្ឋានជាក់ស្តែងមួយនៃសាមគ្គីភាពសង្គមគឺថាមវន្ត។ គោលគំនិត និយមន័យ និងវិមាត្រ អាចត្រូវគេចាត់ទុក ថាមានការវិវត្តឥតឈប់ឈរដើម្បីរំលេចបរិបទនៃការងាររបស់ពួកគេ។

ពួកគេសង្ខេបសាមគ្គីភាពសង្គមក្នុងពេលជាក់លាក់មួយ ទាក់ទងទៅនឹងលក្ខណៈសង្គមនៃប្រទេសក្នុងគ្រាដែលធ្វើជាគំរូ។ បន្ទាប់មក ពួកគេអាចផ្លាស់ប្តូរដើម្បីបង្ហាញពីវឌ្ឍនភាព ឬកង្វះវឌ្ឍនភាព។

ដើម្បីធ្វើចំណាត់ថ្នាក់ឱ្យបានចំៗ គោលគំនិតនៃសាមគ្គីភាពសង្គមបត់បែនដោយគ្មានចំណុចបញ្ចប់ជាក់លាក់។ ពាក្យនេះអាចវិភាគបានទាំងផ្នែកសិក្សា និងផ្នែកគាក់តែងគោលនយោបាយ។ ទោះជាយ៉ាងណា របាយការណ៍នេះនឹងប្រើប្រាស់ការពិភាក្សាស្តីពីគោលនយោបាយដោយសារភាពសមស្របរបស់វា សម្រាប់ភាពច្បាស់លាស់និងការយល់ឃើញក្នុងបរិបទរបស់ប្រទេសកម្ពុជា។ ជាពិសេស ទំនាក់ទំនងបច្ចុប្បន្ន រវាងសន្តិភាពនិងឯកភាពគ្នា ត្រូវតែស្វែងយល់ក្នុងបរិបទនៃប្រទេសកម្ពុជាដែលជាបុព្វហេតុនៃការអភិវឌ្ឍតាមរយៈសាមគ្គីភាពសង្គម។

ជាលក្ខណៈធម្មជាតិ ការឯកភាពគ្នាគឺត្រូវស្នើឱ្យមានការជឿជាក់ស្ថិតស្ថេររួមមួយក្នុងជួរប្រជាពលរដ្ឋជុំវិញគោលដៅរួមមួយ។

ក្រោយពីរបបខ្មែរក្រហម និងបន្ទាប់មកនៅសម័យអ៊ុនតាក់ បានផ្តល់នូវមូលដ្ឋានគ្រឹះយ៉ាងរឹងមាំនៃសន្តិភាព។ តាមរយៈនេះការរីកចម្រើន (ទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម) ចាប់ផ្តើមរីកដូចផ្សិត។ ផ្ទុយទៅវិញ ការចាក់គ្រឹះនេះត្រូវទុកផ្លូវសម្រាប់គំនិតកាន់តែទូលំទូលាយសម្រាប់ទ្រទ្រង់សន្តិភាព។ ខណៈដែលព្រះរាជាណាចក្រកម្ពុជាបន្តការរីកចម្រើនរបស់ខ្លួនយ៉ាងលឿន សង្គមក៏នឹងបន្តធ្វើពិពិធកម្មតាមអាយុ ការអប់រំ តាមសាសនា ជាតិសាសន៍ ទំនោរផ្លូវភេទ និងឱកាសសេដ្ឋកិច្ច(មានមួយចំនួន)។ ការណ៍នេះទាមទារការយល់ឃើញចម្រុះដើម្បីចាប់យកឱ្យបានត្រឹមត្រូវនូវភាពមិនចុះសម្រុងគ្នា គាំទ្រការយល់ដឹងផ្នែកនយោបាយក្នុងស្រទាប់ប្រជាជន និងដើម្បីការចូលរួមឱ្យបានត្រឹមត្រូវរបស់ជនស៊ីវិល។

អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ឱ្យនិយមន័យសង្គមមានសាមគ្គីភាពសង្គមថាជាសង្គមដែល “ធ្វើការដើម្បីសុខុមាលភាពរបស់សមាជិកទាំងអស់នៅក្នុងសង្គមប្រឆាំងទៅនឹងការផាត់ចោលនិងភាពមិនអើពើក្នុងសង្គម បង្កលក្ខណៈឱ្យសមាជិកទាំងអស់មានអារម្មណ៍ចូលចំណោមគ្នា លើកកម្ពស់ការជឿទុកចិត្តគ្នា និងផ្តល់លទ្ធភាពឱ្យគ្រប់គ្នាមានឱកាសរីកចម្រើននៅក្នុងសង្គម”[11]។ តាមរយៈនិយមន័នេះ អង្គការ OECD វាស់វែងសាមគ្គីភាពសង្គមដោយប្រើវិមាត្រចំនួនបី គឺ បរិយាបន្នសង្គម មូលធនសង្គម និងចល័តភាពសង្គម។

- **បរិយាបន្នសង្គម៖** ពិនិត្យមើលទៅលើវិសាលភាពនៃការផាត់ចេញនិងការចាត់ទុកជាបន្ទាប់បន្សំ មានដូចជាភាពក្រី, វិសមភាព និងភាពបែកខ្ញែកក្នុងសង្គម។
- **មូលធនសង្គម៖** សំដៅលើបណ្តាញនៃទំនាក់ទំនងរវាងបុគ្គល និងក្រុម កម្រិតនៃការទុកចិត្តគ្នាក្នុងចំណោមបុគ្គល និងសង្គម កម្រិតនៃការចូលរួមរបស់ពលរដ្ឋ[12]។

[10] Ibid.

[11] OECD (2011). Perspectives on Global Development 2012: Social Cohesion in a Shifting World, OECD Publishing.

[12] Ibid

- **ចល័តភាពសង្គមៈ** គឺជាកម្រិតលទ្ធភាពដែលបុគ្គលអាច ឬមួយក៏ត្រូវបានគេជឿថាអាចមានសម្រាប់កែលម្អស្ថានភាពរបស់ខ្លួននៅក្នុងសង្គម។

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) មាននិយមន័យរបស់ខ្លួនដោយឡែក ស្តីពីសាមគ្គីភាពសង្គមនិងវិមាត្ររបស់វា។ យោងតាមយូអិនឌីភី សាមគ្គីភាពសង្គមអាចចងក្រងជាគោលគំនិតបានតាមរយៈវិមាត្រពីរៈ សាមគ្គីភាពសង្គមតាមខ្សែឈរ(ខ្សែទទឹង) ដែលនិយាយពីទំនាក់ទំនងរវាងពលរដ្ឋនិងរដ្ឋាភិបាលរបស់ខ្លួន និងសាមគ្គីភាពសង្គមតាមខ្សែដេក(ខ្សែបណ្តោយ) ដែលនិយាយពីទំនាក់ទំនងរវាងពលរដ្ឋ និងរវាងក្រុមនានានៅក្នុងសង្គម[13]។

- សាមគ្គីភាពសង្គមតាមខ្សែឈរ ឬដែលមានរដ្ឋជាតួអង្គស្នូល រៀបរាប់អំពីកម្រិតនៃការជឿទុកចិត្តទៅលើរដ្ឋាភិបាលនិងដំណើរការស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬថ្នាក់មូលដ្ឋាន ឧទាហរណ៍ ការបោះឆ្នោត លទ្ធភាពទទួលបានសេវាយុត្តិធម៌ និងសេវាសាធារណៈ។ សាមគ្គីភាពសង្គមនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការធ្វើយ៉ាងណាឱ្យមានការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព លើកកម្ពស់ដំណើរការនយោបាយនិងនយោបាយសាធារណៈបែបបរិយាបន្ន ការជឿទុកចិត្ត ភាពស្របច្បាប់ ការជឿជាក់ថាពលរដ្ឋក៏នឹងទទួលស្គាល់អំពីការខិតខំរបស់រដ្ឋាភិបាល ស្ថាប័ន និងដំណើរនយោបាយដែរ។
- សាមគ្គីភាពសង្គមតាមខ្សែដេក ឬដែលមានសង្គមជាស្នូល រៀបរាប់ពីសតិអំពីការជឿទុកចិត្តទំនាក់ទំនង និងអន្តរកម្មក្នុងចំណោមពលរដ្ឋដែលមានអត្តសញ្ញាណផ្សេងគ្នា ឬរចនាសម្ព័ន្ធសង្គមខុសៗគ្នា និងអំពីរបៀបដែលអង្គការសង្គម សង្គមស៊ីវិល និងស្ថាប័នសង្គមសម្តែងឱ្យឃើញនូវភាពអាស្រ័យគ្នាទៅវិញទៅមក និង “ជោគវាសនារួម” នៅក្នុងសង្គម។ នៅក្នុងទំនាក់ទំនងតាមខ្សែដេកនេះមានៈ ជាចំណងនៃមូលធនសង្គម-ឧទាហរណ៍ការជឿទុកចិត្ត និងការផ្សារភ្ជាប់នៅក្នុងបណ្តាក្រុមដែលមានផលប្រយោជន៍រួម។ ជាស្ពាននៃមូលធនសង្គម - ឧទាហរណ៍ទំនាក់ទំនងនិងបណ្តាញដែលលាតសន្ធឹងតាមក្រុម និងផ្នែកនានានៃសង្គម។ ជាតំណភ្ជាប់នៃមូលធនសង្គម- ឧទាហរណ៍សហប្រតិបត្តិការនៅតាមអង្គការសង្គម ស្ថាប័ន មេដឹកនាំ តួយ៉ាងអង្គការអន្តរជំនឿសាសនា ជាដើម[14]។

  នៅតាមវិមាត្រខ្សែឈរ និងខ្សែដេក មានអនុវិមាត្រចំនួន១៤។ អនុវិមាត្រទាំងនោះរួមមានៈ ការជឿទុកចិត្ត ភាពចូលចំណោម (ឬជោគវាសនារួម) បរិយាបន្ន ភាពពឹងអាស្រ័យទៅវិញទៅមក សន្តិសុខមនុស្ស ផ្នត់គំនិតអវិជ្ជមាន ការភ័យបារម្ភរវាងក្រុមនិងក្រុមគម្លាតសង្គម ការយល់ឃើញថាមានការគំរាមផ្នែកសង្គម អារម្មណ៍វិជ្ជមាន គម្លាតវប្បធម៌ ឧបនិស្ស័យក្នុងការអត់ឱន ឧបនិស្ស័យក្នុងការចងពៀរ និងការទាក់ទងរវាងក្រុមនឹងក្រុម[15]។

ក្នុងការពិនិត្យមើលទៅលើវិមាត្រទាំងនេះ និងលក្ខណៈរបស់វា គេនឹងសម្គាល់ឃើញថាគ្មានការប៉ុនប៉ងជាក់លាក់ណាមួយក្នុងការកំណត់និយមន័យឱ្យពាក្យ សាមគ្គីភាពសង្គម នេះទេ។ នៅក្នុងការប៉ុនប៉ងក្នុងការកែតម្រូវទៅលើនិយមន័យខុសៗគ្នា(នៃពាក្យសាមគ្គីភាពសង្គម)អ្នកនិពន្ធ Chan et.al[16] បានស្នើឡើងនូវនិយមន័យកម្រិតអប្បបរមាមួយ(នៃពាក្យសាមគ្គីភាពសង្គម)។

គេធ្វើដូច្នេះតាមរយៈការវិភាគលើអ្វីដែលគេធ្លាប់បានលើកឡើងថាមានភាពស្រពេចស្រពិលច្រើននៅក្នុងការឱ្យនិយមន័យពាក្យ សាមគ្គីភាពសង្គម ពេលណាវាត្រូវបានយកមកប្រើរួមគ្នាតាមអភិក្រមមធ្យោបាយ-គោលដៅ (means-end approach) និងអភិក្រមចម្រុះ (pluralistic approach)៖

- គោលវិធីមធ្យោបាយ-គោលដៅៈ សាមគ្គីភាពសង្គម ជាគោលដៅចុងក្រោយ ដែលត្រូវសម្រេចឱ្យបាន មិនថាអាចមានអ្វីកើតឡើងនៅតាមផ្លូវទេ។

---

[13] UNDP (2020). Strengthening Social Cohesion: Conceptual Framing and Programming Implications, UNDP.

[14] Ibid.

[15] Ibid.

[16]

- គោលវិធីចម្រុះ៖ បោះបង់ចោលការព្យាយាមកំណត់និយមន័យតែមួយគត់ឱ្យពាក្យនេះ។

Chan et al. លើកទន្ទឹករថា សាមគ្គីភាពសង្គម សំដៅលើការណ៍ថាតើមនុស្សក្នុងសង្គម នៅជាមួយគ្នា ‘‘cohere’’ ឬល្អុកល្អិនជាមួយគ្នា ‘‘stick’’ បានល្អឬយូរប៉ុនណា។ នៅក្នុងសង្គម មនុស្សត្រូវបានគេយល់ឃើញថាមានភាព “ល្អុកល្អិនជាមួយគ្នា” តែកាលណាបំពេញបាននូវលក្ខណ្ឌវិនិច្ឆ័យបីខាងក្រោមនេះ ប៉ុណ្ណោះ៖

១. ពួកគេអាចជឿទុកចិត្តគ្នា ជួយគ្នា និងសហការគ្នាជាមួយសមាជិកដទៃក្នុងសង្គម។
២. មានអត្តសញ្ញាណរួម ឬមានសតិពីភាពចូលចំណោមរួមគ្នានៅក្នុងសង្គម។
៣. អារម្មណ៍អត្តនោម័តនៅក្នុងចំណុចទី (១) និងទី (២) បង្ហាញជាក់ស្តែងតាមរយៈអាកប្បកិរិយាសត្យានុម័ត[17]។

អាស្រ័យហេតុនេះ សាមគ្គីភាពសង្គម ត្រូវបានចាត់ទុកថាជា

ស្ថានភាពមួយពាក់ព័ន្ធអន្តរកម្មរវាងសមាជិកក្នុងសង្គមទាំងតាមខ្សែឈរនិងខ្សែដេក ដូចត្រូវបានពន្យល់ដោយសំណុំឥរិយាបថនិងបទដ្ឋាន ដែលក្នុងនោះមាន ការជឿទុកចិត្ត អារម្មណ៍ពីភាពចូលចំណោម និងឆន្ទះចូលរួមជួយ ព្រមទាំងការធ្វើអាកប្បកិរិយាជាក់ស្តែងផងដែរ។ ស្រដៀងគ្នាទៅនឹងការចងក្រងគោលគំនិតដោយអង្គការយូអិនឌីភីដែរ អន្តរកម្មតាមខ្សែឈរ សំដៅលើទំនាក់ទំនងរវាងរដ្ឋនិងសង្គមទាំងមូល រីឯអន្តរកម្មតាមខ្សែដេក សំដៅលើអន្តរកម្មក្នុងចំណោមបុគ្គល ឬក្រុមផ្សេងៗនៃសង្គម[18]។ In addition, the referenced materials above, The Social Cohesion Radar (SCR) defines social cohesion as a quality of social cooperation and togetherness in a territorially delimited community that is expressed in the attitudes and behaviors of its members.

ក្រៅពីឯកសារយោងមួយចំនួនខាងលើដែលបានលើកឡើងនៅខាងលើ ស្ថាប័ន Social Cohesion Radar (SCR) បានឱ្យនិយមន័យសាមគ្គីភាពសង្គមថាជា គុណភាពនៃសហប្រតិបត្តិការក្នុងសង្គម និងការរួមរស់ជាមួយគ្នា នៅក្នុងរង្វង់ដែនសហគមន៍មួយ ដែលត្រូវបានស្តែងចេញតាមរយៈឥរិយាបថនិងអាកប្បកិរិយារបស់សមាជិកសហគមន៍នោះ។ យោងតាម SCR សង្គមមួយមានសាមគ្គីភាពសង្គមគឺដោយសារមានទំនាក់ទំនងសង្គមស្វិតស្វាញ ស្មារតីផ្សារភ្ជាប់គ្នាជាវិជ្ជមាន និងការផ្តោតស្មារតីខ្លាំងទៅលើប្រយោជន៍រួម[19]។ តារាងទី១នៅខាងក្រោមមាននិយមន័យផ្សេងៗគ្នាពីអង្គការទាំងបីខាងលើ។

**តារាងទី១៖ និយមន័យអំពីភាពស្អិទ្ធស្អាលសង្គម[20]**

| OECD (2011) | UNDP (2020) | SCR (2021) |
|---|---|---|
| សង្គមមានសាមគ្គីភាពសង្គមជាសង្គមដែល “ធ្វើការដើម្បីសុខុមាលភាពរបស់សមាជិកទាំងអស់នៅក្នុងសង្គម ប្រឆាំងទៅនឹងការ | យូអិនឌីភី ចងក្រងគោលគំនិតស្តីពីសាមគ្គីភាពសង្គម តាមរយៈវិមាត្រពីរ៖ សាមគ្គីភាពសង្គមតាមខ្សែឈរ ដែលនិយាយពីទំនាក់ទំនងរវាង | “សាមគ្គីភាពសង្គម ជាគុណភាពនៃសហប្រតិបត្តិការក្នុងសង្គម និង ការរួមរស់ជាមួយគ្នា នៅក្នុងរង្វង់ដែនសហគមន៍មួយ ដែលត្រូវបានស្តែងចេញ |

[17] Ibid.
[18] Ibid.
[19] Social Cohesion Asia. (2021). Retrieved 12 November 2021, from https://www.bertelsmann-stiftung.de/de/unsere-projekte/deutschland-und-asien/social-cohesion-asia
[20] Alternative sources on Social Cohesion exist beyond the three discussed in this paper's conceptualisation. This includes the work of Kim,J., Sheely, R., Schmidt, C. (2020). Social Capital and Social Cohesion Measurement Toolkit for Community-Driven Development Operations. Washington DC: Mercy Corps and The World Bank Group.

| | | |
|---|---|---|
| ផាត់សំបកនិងចាត់ទុកអ្នកឯទៀតជាមនុស្សបន្ទាប់បន្សំក្នុងសង្គម បង្កលក្ខណៈឱ្យសមាជិកទាំងអស់មាន អារម្មណ៍ចូលចំណោមគ្នា លើកកម្ពស់ការជឿទុកចិត្តគ្នា និងផ្តល់លទ្ធភាពឱ្យគ្រប់គ្នាមានឱកាស រីកចម្រើនឡើង នៅក្នុងសង្គម”។ | ពលរដ្ឋ និងរដ្ឋាភិបាលរបស់ខ្លួន និងសាមគ្គីភាពសង្គម តាមខ្សែដេក ដែលនិយាយពីទំនាក់ទំនងរវាងពលរដ្ឋ និងរវាងក្រុមនានានៅក្នុងសង្គម”។ | តាមរយៈឥរិយាបថ និងអាកប្បកិរិយារបស់សមាជិកសហគមន៍នោះ”។ |

មុននឹងឈ្វេងយល់អំពីសាមគ្គីភាពសង្គមក្នុងបរិបទប្រទេសកម្ពុជា យើងគប្បីយល់នូវការប្រើប្រាស់ទូលំទូលាយនៃពាក្យនេះ(សាមគ្គីភាពសង្គម)នៅក្នុងបរិបទតំបន់ "តំបន់អាស៊ី"ជាមុនសិន។ អាស៊ីស្ថិតក្នុងចំណោមតំបន់ដែលមានពូជសាសន៍ចម្រុះលើពិភពលោក។ តំបន់នេះបានឆ្លងកាត់ការបរិវត្តកម្មយ៉ាងលឿននិងស៊ីជម្រៅផ្នែកសង្គមសេដ្ឋកិច្ច និងនយោបាយ នៅក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ[21]។ យ៉ាងណាក្តី គោលគំនិតស្តីពីសាមគ្គីភាពសង្គម ហាក់ដូចជាមិនត្រូវបានយកទៅអនុវត្តជាលក្ខណៈប្រព័ន្ធនៅឡើយទេ។ អាចដែរថា តំបន់នេះមិនបានប្រើប្រាស់ពាក្យសាមគ្គីភាពសង្គមនេះឱ្យបានជាក់លាក់មែន ប៉ុន្តែគេប្រើប្រាស់គោលគំនិតផ្សេងទៀត មានដូចជាពាក្យ ភាពសុខដុមសង្គម, សមាហរណកម្មសង្គម, ឯកភាព និងបរិយាបន្នសង្គម[22]។ ការវិភាគមួយរបស់ SCR[23] បានរំលេចឱ្យឃើញថា បណ្តាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿននៅអាស៊ី ហាក់ដូចជាមានសូចនាករស្តីពីសាមគ្គីភាពសង្គមរឹងមាំជាង[24]។ ដូចបានលើកឡើងមុននេះ នៅកម្ពុជា ពាក្យ “unity” ជាច្រើនត្រូវបានគេប្រែជាខ្មែរថា “សាមគ្គីភាព”។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរលំ រាជរដ្ឋាភិបាលកម្ពុជាបានប្រើចង្កោមពាក្យ “សន្តិភាព និង ការរួបរួម” “peace and unity” ជាមធ្យោបាយសម្រាប់ឈានទៅសម្រេចសេចក្តីប្រាថ្នាលើការអភិវឌ្ឍជាតិ ក្នុងផ្នែកសេដ្ឋកិច្ច នយោបាយ និងភាពសុខដុមសង្គម។

បើនិយាយអំពីធនធានឯកសារសម្រាប់ស្រាវជ្រាវជាក់លាក់អំពីសាមគ្គីភាពសង្គមនៅកម្ពុជាវិញ បច្ចុប្បន្នគឺពិបាករកបានណាស់។ យ៉ាងណាមិញ ចំណុចដែលត្រូវកត់សម្គាល់ គឺថា កម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួន២២ ដែលត្រូវបានលើកយកមកធ្វើការវាយតម្លៃអំពីសាមគ្គីភាពសង្គម នៅក្នុងរបាយការណ៍របស់ SCR ដូចបានលើកឡើងនៅខាងលើ។

យោងតាម SCR ការរៀបចំគោលគំនិតស្តីពីសាមគ្គីភាពសង្គមមានសមាសភាគបីផ្នែក ដែលផ្នែកនីមួយៗមានវិមាត្រអាចវាស់វែងបានចំនួនបី (គំនូសតាងទី២ខាងក្រោម)៖

- ទំនាក់ទំនងសង្គម៖ បណ្តាញសង្គម ការជឿទុកចិត្តលើប្រជាជន និងការទទួលយកពិពិធភាព។

---

[21] Croissant, A., & Walkenhorst, P. (2021). Social Cohesion in Asia: Historical Origins, Contemporary Shapes and Future Dynamics (pp. 1-25). Oxon: Routledge.

[22] Ibid.

[23] Social Cohesion Radar is a project initiated by the Bertelsmann Stiftung to advance research in the field of social cohesion and stimulate the relevant policy debate. The Bertelsmann Stiftung stimulates debate and provides impetus for social change through its projects, studies and events.

[24] Social Cohesion Asia. (2021). Retrieved 12 November 2021, from https://www.bertelsmann-stiftung.de/de/unsere-projekte/deutschland-und-asien/social-cohesion-asia

- ភាពភ្ជាប់គ្នាៈ ការយល់ឃើញអំពីភាពត្រឹមត្រូវ ការជឿទុកចិត្តលើស្ថានប័ន និងអត្តសញ្ញាណកម្ម។
- ប្រយោជន៍រួមៈ ការចូលរួមស៊ីវិល ការគោរពចំពោះក្បួនខ្នាតសង្គម ការសាមគ្គី និងការជួយគ្នា[25]។

**គំនូសតាងទី២ៈ ដូម៉េនស្តីពីសាមគ្គីភាពសង្គមដោយ SCR**




គេអាចឆ្ងល់ថាហេតុអ្វីបានជាសាមគ្គីភាពសង្គមមាននិយមន័យច្រើនម្លេះ និងថាតើនិយមន័យច្រើនបែបនេះអាចជួយដល់ការរៀបចំគោលគំនិតរបស់កម្ពុជាស្តីពីសាមគ្គីភាពសង្គមដោយរបៀបណា។ គោលគំនិតនេះត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ការយល់អំពីកាលានុវត្តភាព និងបញ្ហាប្រឈមជុំវិញសន្តិភាព និងការជឿទុកចិត្តក្នុងចំណោមពលរដ្ឋនិងរដ្ឋនៃសង្គមមួយ។ តាមរយៈនេះគោលគំនិតចាំបាច់ត្រូវទទួលស្គាល់នូវពហុវិមាត្ររបស់ភាពស្អិទ្ធស្អាល ដែលក្នុងនោះកាលណាបរិបទប្រែប្រួល វានឹងនាំឱ្យការរស់វែងប្រែប្រួលតាមហ្នឹងដែរ។ វាសំខាន់ផងដែរនៅក្នុងការកត់សម្គាល់ថារបៀបរស់វែងសាមគ្គីភាពសង្គម ចំណុះតាមគោលបំណងដែលជាកត្តាជំរុញនៅពីក្រោយការស្រាវជ្រាវដែលមាននៅចំពោះមុខ។ សម្រាប់ករណីកម្ពុជា នៅក្នុងឆ្នាំ២០២២ យើងមានចំណាប់អារម្មណ៍ក្នុងការប្រមើលមើលថាតើព្រះរាជាណាចក្រមួយនេះអាចរីកចម្រើនទៅមុខ ដោយសង្កត់ធ្ងន់លើសន្តិភាព

[25] Ibid.

តាមរយៈការឯកភាព និងឆ្ពោះទៅរកសន្តិភាពតាមរយៈការចូលរួម ពិពិធភាព (ភាពចម្រុះ)និង បរិយាបន្ន បានដោយរបៀបណា។

នៅក្នុងន័យនេះ គោលគំនិតនៃសាមគ្គីភាពសង្គមក្នុងបរិបទនៃការអភិវឌ្ឍ កាន់តែមានសារៈសំខាន់ នៅក្នុងការកសាងលទ្ធភាពទទួលបានយុត្តិធម៌ ការរៀបចំកម្មវិធីយុទ្ធសាស្ត្រសម្រាប់ទប់ស្កាត់ជម្លោះ និងសម្រាប់ដំណើរការនយោបាយប្រកបដោយបរិយាបន្ន ការទទួលខុសត្រូវ និងគណនេយ្យភាព ដែលទាំងអស់នេះជាកត្តារួមចំណែកដល់ការសម្រេចគោលដៅនៃការអភិវឌ្ឍដោយចីរភាពសម្រាប់ ជាតិ។

យោងតាមធនាគារពិភពលោក[26] ភាពស្អិតរមួតស្អាលនិងភាពធន់នៃសង្គម បង្កើតកាលានុវត្តភាព សម្រាប់ប្រជាជនដែលរស់នៅក្នុងបណ្តាសង្គមមានសភាពផុយស្រួយ ដើម្បីឱ្យគេអាចមានឱកាស រីកចម្រើនបានតាមរយៈការជួយកសាងក្រុមគ្រួសារនិងសហគមន៍ឱ្យមានភាពរឹងមាំ សម្រាប់ទប់ទល់ ជាមួយភាពប្រេះឆាដែលបង្កឡើងដោយជម្លោះនិងអំពើហិង្សា។ លើសពីនេះ យូអិនឌីភី[27] លើកឡើងថា នៅទីណាដែលការដឹងអំពីចក្ខុវិស័យរួមសម្រាប់អនាគត នោះសាមគ្គីភាពសង្គមនៅទី នោះក៏បង្កើត ភាពធន់ទប់ទល់នឹងការកើនឡើងជម្លោះនៅកម្រិតបុគ្គល ដែលច្រើនតែបណ្តាលមកពីនយោបាយ ប្រទូសរ៉ាយ និង ពេលខ្លះ បណ្តាលមកពីចល័តភាពសង្គមទៅតាមសញ្ញាណ។

ចំណុចសំខាន់មួយទៀតដែលមិនគួរមើលរំលងនៅក្នុងការវិភាគសាមគ្គីភាពសង្គម គឺលទ្ធផលនៃ ភាពស្អិតរមួតស្អាលដែលមានជាធម្មជាតិនៅក្នុង “សង្គមមានសាមគ្គីភាព” ស្រាប់។ និយមន័យទាំងឡាយនៅខាងលើ ធ្វើការសង្កត់ធ្ងន់លើអត្ថន័យសម្រាប់ សន្តិភាពប្រកបដោយចីរភាពតាមរយៈសង្គមស្អិតរមួតស្អាលជាធម្មជាតិ មានន័យថា មិនគួរមានក្រុមណា មួយមានឥទ្ធិពលលើសលប់បង្ខិតបង្ខំឱ្យមានភាពសាមគ្គីភាពសង្គមទេ។ ត្រង់នេះជាចំណុចប្រសព្វ រវាងពេលវេលា និងការអភិវឌ្ឍដើម្បីជំរុញឱ្យមានការសំឡឹងវែងឆ្ងាយហួសពីភាពគ្រាំគ្រាកន្លងមក និង ឆ្ពោះទៅរកភាពបរិយាបន្នបែបរីកចម្រើននិងការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ។ ដូចត្រូវបានលើក ឡើងដោយយូអិនឌីភី ភាពស្អិតរមួតស្អាលអាចជាវេវចនៈសព្ទជំនួសឱ្យពាក្យកាន់កាប់ត្រួតត្រា ដែលត្រូវ បានយល់ថាជាទំនាក់ទំនងចងជាប់នៅក្នុងក្រុមមួយដែលមានអានុភាពលើសលប់ ជាជាងថាជា ស្ពានសម្រាប់ភ្ជាប់គម្លាតនៅក្នុងចំណោមសហគមន៍ផ្សេងៗ[28]។ ឥឡូវនេះគឺជាពេលដែលត្រូវកសាង ស្ពាននោះឡើង។

[26] World Bank (2022) Social Cohesion and Resilience.
[27] UNDP (2020).Strengthening Social Cohesion: Conceptual Framing and Programming Implications, UNDP.
[28] Ibid

## ៣. ការរៀបចំគោលគំនិតស្ដីពីវិមាត្រនៃសាមគ្គីភាពសង្គមនៅកម្ពុជា

របាយការណ៍នេះនឹងថ្លឹងថ្លែងគ្រប់ទិដ្ឋភាពដែលអង្គការយូអិនឌីភី[29] បានលើកឡើង ដោយផ្ដើមចេញពីការឆ្លុះបញ្ចាំងមើលតាមរយៈដំណើរវិវត្តនៃប្រវត្តិសាស្ត្រ សេដ្ឋកិច្ច នយោបាយ និងវប្បធម៌របស់កម្ពុជា។ ជំហានដំបូងត្រូវកំណត់ឱ្យបាននូវទិដ្ឋភាពដើមមួយសំណុំសិន ពីព្រោះវាមានលក្ខណៈសម្បត្តិពាក់ព័ន្ធជាមួយសាមគ្គីភាពសង្គម និងជាមួយសង្គមប្រកបដោយសន្តិភាព និងភាពបរិយាបន្ន[30]។ បន្ទាប់មកទៀត ទន្ទឹករមួយនឹងត្រូវបានបង្កើតឡើងថាតើអនុវិមាត្រណាខ្លះដែលអាចឬមិនអាចអនុវត្តបាននៅកម្ពុជា និងថាតើគេអាចធ្វើកែសម្រួលបែបណាខ្លះដើមឱ្យវាត្រូវគ្នាទៅតាមបរិបទរបស់នៅកម្ពុជា[31]។ លើសពីនេះ ទស្សនាទានពាក់ព័ន្ធផ្សេងៗទៀតតាមរយៈការឱ្យនិយមន័យខុសៗគ្នា ក៏នឹងត្រូវបានយកមកពិចារណាបញ្ចូលឱ្យបានសមស្របដែរ។ មគ្គុទ្ទេសក៍ណែនាំសម្រាប់ពិចារណាទស្សនាទានទាំងនោះមាននៅក្នុងឧបសម្ព័ន្ធ១ នៃរបាយការណ៍។

### វិមាត្រទី១៖ ការជឿទុកចិត្ត

| **ការជឿទុកចិត្ត** | លក្ខណៈសម្បត្តិ/ជំនឿផ្ទាល់ខ្លួនទៅលើមនុស្សណាម្នាក់ ក្រុមឬស្ថាប័នណាមួយ ឬជាការរំពឹងទុកអំពីការដោះដូរ ឬការធ្វើបដិកាទៅវិញទៅមក ដោយសមហេតុសមផល។ |
|---|---|
| ការជឿទុកចិត្តលើសាសនា | ជាការទុកចិត្តផ្អែកលើជំនឿលើស្ថាប័ន ថ្នាក់ដឹកនាំ និងទម្លាប់អនុវត្តរបស់ផ្នែកសាសនា។ |
| ការជឿទុកចិត្តលើស្ថាប័ន | ការទុកចិត្តលើប្រព័ន្ធអភិបាលកិច្ចនយោបាយ។ |
| ការជឿទុកចិត្តលើសហគមន៍ | ជាទំនាក់ទំនងតាមខ្សែដេក និង ការធ្វើអន្តរកម្ម (ឬការប្រាស្រ័យទាក់ទង) ក្នុងចំណោមពលរដ្ឋ[32]។ |
| ការជឿទុកចិត្តលើថ្នាក់ដឹកនាំ | ការទុកចិត្តលើបុគ្គលនៅក្នុងជួរដឹកនាំនយោបាយ។ |

ទស្សនាទានផ្សេងគ្នាអំពីសាមគ្គីភាពសង្គម ជាទូទៅមានគុណលក្ខណៈរួមមួយ គឺការជឿទុកចិត្ត។ សម្រាប់របាយការណ៍នេះ ***ការជឿទុកចិត្ត*** ត្រូវបានឱ្យនិយមន័យថា ជាលក្ខណៈសម្បត្តិ/ជំនឿផ្ទាល់ខ្លួនទៅលើមនុស្សណាម្នាក់, ក្រុម ឬស្ថាប័នណាមួយ ឬជាការរំពឹងទុកអំពីការដោះដូរ ឬការធ្វើបដិកាទៅវិញទៅមក ដោយសមហេតុសមផល។ ការជឿទុកចិត្ត តែងតែមានវត្តមាននៅគ្រប់ទិដ្ឋភាព តាមខ្សែដេក និងខ្សែឈរ នៃសាមគ្គីភាពសង្គម។

មិនខុសពីប្រទេសផ្សេងទេ នៅកម្ពុជាមានសេណារីយោរាប់មិនអស់ដែលតាមរយៈនោះគេតែងសង្កេតឃើញមានបញ្ហាចោទឡើងលើការជឿទុកចិត្តគ្នា។ ពេញមួយប្រវត្តិសាស្ត្ររបស់ខ្លួន កម្ពុជាបានជួបវិបត្តិខ្វះទំនុកចិត្តគ្នាមិនចេះចប់មិនចេះហើយ។

---

[29] UNDP (2020). Strengthening Social Cohesion: Conceptual Framing and Programming Implications, UNDP

[30] Ibid.

[31] It is worth pointing out that under many sub-dimensions, there are multiple uses of the term “adversarial group”. For the purpose of this report, we will be utilizing the language of “different group” in order to ensure conceptual engagement is not undermined by the language employed to represent it.

[32] Defined as the collective group of people who live within the kingdom’s geographical boundaries.

A *trust in religion* forms a prominent sub-dimension for Cambodia. The majority of ethnic Khmer are Theravada Buddhists, from which it is considered that many of the observed Khmer social and psychological characteristics have emerged including conservatism, patience, gentleness, and lack of concern for material wealth.

***ការជឿទុកចិត្តលើសាសនា*** បង្កើតជាទិដ្ឋភាពអនុវិមាត្រដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា។ ជនជាតិខ្មែរភាគច្រើនជាអ្នកពុទ្ធសាសនិកថេរវាទ ដែលត្រូវបានចាត់ទុកថាជាដើមកំណើននៃលក្ខណៈសម្បត្តិផ្នែកសង្គម និងចិត្តសាស្ត្រ ដែលគេសង្កេតឃើញក្នុងចំណោមខ្មែរភាគច្រើន ក្នុងនោះមានភាពអភិរក្សនិយម, ការអត់ធ្មត់, សុភាពរាបសារ និងការមិនសូវខ្វល់ខ្វាយចំពោះសម្បត្តិសម្ភារ[33]។ ពុទ្ធសាសនាថេរវាទជាសាសនារបស់រដ្ឋរហូតដល់ឆ្នាំ១៩៧៥ ហើយត្រូវបានប្រកាសជាសាសនារបស់ឡើងវិញម្តងទៀតនៅឆ្នាំ១៩៩៣។ ជាមួយគ្នានេះ សំខាន់ណាស់ដែលត្រូវរំឭកថា ប្រជាជនកម្ពុជាទាំងអស់មិនមែនសុទ្ធតែជាខ្មែរទេ ហើយក៏មិនមែនសុទ្ធតែជាពុទ្ធសាសនិកដែរ។ មានក្រុមជនជាតិខ្មែរលើដែលកាន់សាសនាដោយឡែករបស់ខ្លួន រីឯជនជាតិវៀតណាម និងចិន តែអាចកាន់ព្រះពុទ្ធសាសនាមហាយាន សាសនាតាវ ឬសាសនារ៉ូម៉ាំងកាតូលិក។ សហគមន៍ចាមគឺជាអ្នកកាន់សាសនាឥស្លាម ខណៈពេលដែលខ្មែរនៅតាមទីក្រុងជាច្រើនបានងាកទៅកាន់សាសនាប្រូតេស្តង់វិញ។ ដូច្នេះ អនុវិមាត្រនៃការទុកចិត្តដើរតួសំខាន់ខ្លាំងណាស់ សម្រាប់ស្វែងយល់អំពីសក្តានុពលនាំឱ្យមានភាពស្និទ្ធស្នាល ឬការបាក់បែកក្នុងសង្គម។ អ្វីដែលគួរកត់សម្គាល់ គឺវាបញ្ជាក់ច្បាស់ថាហេតុអ្វីបានជាគោលគំនិត “ឯកភាព” មិនអាចជាលក្ខណៈសម្បត្តិមួយមាននិរន្តភាពសម្រាប់សន្តិភាព។

តាមទស្សនៈពុទ្ធសាសនាថេរវាទ ការប្រកាន់ខ្ជាប់នូវឱវាទសាសនាជាគ្រឹះទ្រទ្រង់ដល់ការគោរពចំពោះរាជាធិបតេយ្យ និងភាពល្បីល្បាញជាប្រវត្តិសាស្ត្ររបស់ប្រាសាទអង្គរ។ ជំនឿបែបនេះត្រូវបានឆ្លុះបញ្ចាំងតាមទស្សនៈមួយដែលថា ប្រជាជនបានប្រគល់វាសនារបស់ពួកគេនៅដាក់ក្នុងដៃរបស់អ្នកដឹកនាំ ដែលកើតមកដើម្បីដឹកនាំពួកគេ។ ផ្អែកលើជំនឿនេះ ប្រជាជននាំគ្នាយល់ព្រមទទួលយកថា តួនាទីរបស់ខ្លួននៅក្នុងសង្គម គឺជាអ្វីដែលជោគវាសនាបានកំណត់ឱ្យរួចហើយ។

គេអាចសង្កេតឃើញថា ជំនឿបែបនេះទៅលើថ្នាក់ដឹកនាំដែលជោគវាសនាបានកំណត់មកតាំងពីជំនាន់អាណានិគមបារាំងកាន់កាប់ម្ល៉េះ ហើយវាជាឧទាហរណ៍មួយស្តីពី ***ការជឿទុកចិត្តលើស្ថាប័ន***។

ត្រង់ចំណុចនេះ សំខាន់ត្រូវធ្វើការញែកឱ្យដាច់ដោយឡែកពីគ្នារវាង ការទុកចិត្តផ្អែកលើប្រព័ន្ធ និងការទុកចិត្តផ្អែកលើតួអង្គ នីមួយៗ។ ការទុកចិត្តផ្អែកលើប្រព័ន្ធ សំដៅលើការយល់ឃើញអំពីការទុកចិត្តលើស្ថាប័ន, លើទម្លាប់អនុវត្តន៍ និងទៅលើដំណើរការកិច្ចការ។ ចំណែក ការទុកចិត្តផ្អែកលើតួអង្គ វិញ គឺសំដៅលើការទុកចិត្តលើបុគ្គលនីមួយៗដែលជាតំណាងរបស់ស្ថាប័ន ដូចជានាយករដ្ឋមន្ត្រី ឬ មេភូមិ ជាដើម។ នៅក្នុងបរិបទកម្ពុជា ជារឿយៗ ស្ថាប័នទទួលការវិនិច្ឆ័យតាមរយៈការទុកចិត្តផ្អែកលើតួអង្គ ដែលជាតំណាងនៃស្ថាប័នទាំងនោះ។

អនុវិមាត្រត្រូវបានកំណត់ថាជាការទុកចិត្តលើប្រព័ន្ធអភិបាលកិច្ច មិនមែនលើតួអង្គទេ។ តួអង្គត្រូវបានលើកយកមកនិយាយជាផ្នែកមួយនៃការទុកចិត្តលើថ្នាក់ដឹកនាំ។ ការយកពន្ធខ្ពស់ និងការវិនិយោគតិចតួចទៅលើវិស័យអប់រំ សុខភិបាល ឬប្រព័ន្ធយុត្តិធម៌[34] ទាំងអស់នេះគួបគ្នាធ្វើឱ្យប្រជាជនកម្ពុជាកើតក្តីមន្ទិលក្នុងចិត្តច្រើន។ ក្តីមន្ទិលនេះបានរីកធំក្លាយទៅជាការមិនសប្បាយចិត្តនៅក្នុងស្រទាប់ប្រជារាស្ត្រ ក្រោយសម័យសង្គ្រាមលោកលើកទី២ និងក្រោយមកទៀតមួយរយៈខ្លីក្នុងសម័យកម្ពុជាក្លាយជារដ្ឋឯករាជ្យ។ ក្រោយសង្គ្រាមលោកលើកទី២ បារាំងបានវិលមកកាន់កាប់កម្ពុជាវិញភ្លាម ហើយការដកលោក សឺង ង៉ុកថាញ់ ចេញពីតំណែងបណ្តោះអាសន្ន បានសាបព្រួសពូជនៃចលនាទាមទារឯករាជ្យទាំងស្រុងពីបារាំង។ ក្រោមព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យរបស់ព្រះអង្គម្ចាស់នរោត្តមសីហនុ កម្ពុជាទទួលបានឯករាជ្យទាំងស្រុង ប៉ុន្តែនៅរក្សាទំនាក់ទំនងជិតស្និទ្ធជា

[33] Britannica (2022)

[34] Chandler (2003) *An end to 90 years of colonialism ‘sans heurts’*, The Phnom Penh Post.

មួយបារាំងដដែល។ និយាយឱ្យខ្លី ចាប់ពីពេលនោះមកបាន កម្ពុជារអិលខ្លួនចូលក្នុងសង្គ្រាមត្រដាក់រហូតដល់រដ្ឋប្រហារទម្លាក់សម្តេចសីហនុចេញពីតំណែងប្រមុខរដ្ឋ រុញប្រទេសឱ្យធ្លាក់ទៅក្នុងសង្គ្រាមបង្ហូរឈាមផ្ទៃក្នុង ការកាន់កាប់ដោយរបបខ្មែរក្រហមមុននឹងវាត្រូវបានផ្តួលរំលំនៅដើមឆ្នាំ១៩៧៩។ ចាប់តាំងពីពេលនោះមក ប្រព័ន្ធគ្រប់គ្រងនៅកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរច្រើន រួមទាំងត្រូវស្ថិតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់អ៊ុនតាក់ ដែលរៀបចំការបោះឆ្នោតពហុបក្សបង្កើតបានប្រព័ន្ធគ្រប់គ្រងដែលមានរហូតមកដល់សព្វថ្ងៃនេះ។

ទោះបីជាមានការផ្លាស់ប្តូរជាវិជ្ជមានក៏ដោយ កម្ពុជានៅតែជាប់ជិតដាមដោយកង្វះទុកចិត្តគ្នា ពីជំនាន់ទៅមួយជំនាន់ ដោយសារតែមកពីសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ។ គេអាចក្រឡេកក្រោយទៅសិក្សាមើលអំពីតម្រូវការចាំបាច់ដាក់ស្តែងដើម្បីឱ្យតែនៅរស់រានមានជីវិត ក្រោមរបបខ្មែរក្រហម។ សេចក្តីលំបាកវេទនាបានតម្រូវឱ្យមនុស្សប្រកាន់យកផ្នត់គំនិតអាត្មានិយមយកតែមួយរស់ ដែលបង្កឱ្យមានការមិនទុកចិត្តគ្នា រហូតដល់ទៅមនុស្សហ៊ានរាយការណ៍អំពីគ្នាទៅវិញទៅមកទៀតផង[35]។ ការចងចាំអំពីសង្គ្រាមនៅតែជាស្រមោលតាមអន្ទោលស្មារតីជនកម្ពុជាជានិច្ច ធ្វើឱ្យប៉ះពាល់ដល់អនុវិមាត្រខាងលើ បន្ថែមពីលើ ***ការជឿទុកចិត្តលើសហគមន៍*** និង ***ការជឿទុកចិត្តលើថ្នាក់ដឹកនាំ***។

ការជឿទុកចិត្តលើសហគមន៍ សំដៅលើទំនាក់ទំនងខ្សែដេក និងការប្រាស្រ័យទាក់ទងរវាងមនុស្សនៅក្នុងសង្គម ឧទាហរណ៍ រវាងក្រុមមនុស្សដែលមានលក្ខណៈប្រជាសាស្ត្រ, ផលប្រយោជន៍ និងសកម្មភាពប្រចាំថ្ងៃខុសៗគ្នា។ ការទុកចិត្តលើសហគមន៍ គឺជាលក្ខខណ្ឌបរិយាកាសដែលធ្វើឱ្យមនុស្សម្នាមានសេចក្តីសុខផ្លូវចិត្ត ក្នុងការបំពេញកិច្ចការប្រចាំថ្ងៃរបស់ខ្លួន ដោយមិនព្រួយបារម្ភអំពីការធ្វើទុកបុកម្នេញ ឬ ការសងសឹកណាមួយ។

រីឯការជឿទុកចិត្តលើថ្នាក់ដឹកនាំ វាសំដៅលើការទុកចិត្តដែលផ្អែកលើគុណសម្បត្តិ ដែលមានមកជាមួយតួអង្គនយោបាយ ឬក្នុងរដ្ឋាភិបាល។

ដូចបានលើកឡើងមុននេះ យើងឃើញថាមានភាពខុសគ្នារវាងការទុកចិត្តលើតួអង្គ និងការទុកចិត្តលើស្ថាប័ន ប៉ុន្តែក៏នៅតែមានភាពច្របូកច្របល់គ្នារវាងការទុកចិត្តទាំងពីរប្រភេទនេះ ជាពិសេសពាក់ព័ន្ធនឹងរូបលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវបានមនុស្សជាច្រើនយល់ឃើញថា ក្តាប់អំណាចច្រើននៅក្នុងដៃ មានអំណាចនីតិបញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

ទិដ្ឋភាពស្មុគស្មាញអាចសង្កេតឃើញមាននៅក្នុងការទុកចិត្តតាមរយៈខ្សែឈរ។ ឧទាហរណ៍ ក្នុងការបោះឆ្នោតឃុំសង្កាត់ ប្រជាជនអាចបោះឆ្នោតឱ្យគណបក្សណាមួយពិតមែន ប៉ុន្តែមិនមែនដោយសារគេទុកចិត្តលើគណបក្សនោះទេ តែគឺមកពីគេមានសេចក្តីទុកចិត្តលើមេឃុំ ឬ មេភូមិ ដែលជាតំណាងរបស់គណបក្ស។ ហេតុនេះ យកល្អគួរតែសិក្សាថែមទៀតអំពីការទុកចិត្ត នៅក្នុងគោលគំនិតថាតើបុគ្គល ឬ ស្ថាប័ន ដែលជាតំណាងឱ្យកម្ពុជា ជាជាងការគ្រាន់តែវាយតម្លៃសើៗពីខាងក្រៅទៅលើបុគ្គល ឬស្ថាប័ន។ ក្នុងន័យនេះ គេអាចពិនិត្យមើលការទុកចិត្តតាមរយៈទិដ្ឋភាពតូចៗផ្សេងទៀត នៅតាមខ្សែឈរ (ថ្នាក់ដឹកនាំ ស្ថាប័ន និង សាសនា) និងនៅតាមខ្សែដេក (សហគមន៍)។

កាលណាមើលពីជ្រុងសេដ្ឋកិច្ច ការទុកចិត្តក៏ជាកម្មវត្ថុនៃការចោទសួរដែរ។ ថ្វីដ្បិតតែមានវឌ្ឍនភាពនៅក្នុងការអភិវឌ្ឍប្រទេសក្តី គេតែឃើញមានការមិនពេញចិត្តកើតឡើងនៅក្នុងសង្គមកម្ពុជា ជាពិសេសរវាងពលរដ្ឋដែលរស់នៅតាមទីប្រជុំជននិងពលរដ្ឋរស់នៅជនបទ ពលរដ្ឋដែលមានដើមកំណើតខ្មែរនិងមិនមែនខ្មែរ អ្នកដែលទទួលបានការអប់រំនៅសាកលវិទ្យាល័យ និង អ្នកដែលទទួលបានការអប់រំតិចតួច ល និង ល។

ការជឿទុកចិត្តគឺជាវិមាត្រដ៏សំខាន់មួយសម្រាប់វាយតម្លៃសាមគ្គីភាពសង្គមកម្ពុជា ព្រោះវាក្រសោបនូវការប្រាស្រ័យទាក់ទងជាច្រើនស្រទាប់នៅក្នុងចំណោមពលរដ្ឋកម្ពុជា ហើយនៅតែធ្វើបរិវត្តឥតឈប់ឈរ ស្របតាមការប្រែប្រួលក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រ នយោបាយ សេដ្ឋកិច្ច និងសង្គម។ ដូចបានលើកឡើងនៅខាងលើកន្លងមក សាមគ្គីភាពសង្គមអាចផ្តុំបង្កើតជាគោលគំនិត នៅតាមទិដ្ឋភាពខ្សែឈរ និងខ្សែដេក។ នៅកម្ពុជា វិមាត្រស្តីពីការទុកចិត្តមានសភាពស្មុគស្មាញគួរសម ព្រោះ

[35] Kiernan, B. (2008). Pol Pot Regime 1975-79: Race, Power, and Genocide in Cambodia under the Khmer Rouge. Yale University Press.

ថា ជួនកាល ការយល់ឃើញរបស់ពលរដ្ឋម្នាក់អំពីបុគ្គលតួអង្គណាមួយ មិនបានញែក គុណលក្ខណៈរបស់តួអង្គ និងគុណលក្ខណៈរបស់ប្រព័ន្ធឬស្ថាប័ន ឱ្យដាច់ដោយឡែកពីគ្នាទេ។

ទិដ្ឋភាពរួមស្តីពីសូចនាករ ប្រភព និងវិធីសាស្ត្រ មាននៅក្នុងតារាងវិមាត្រ១។

### វិមាត្រទី ២៖ ភាពចូលចំណោម

| **ភាពចូលចំណោម** | គោលគំនិតស្តីពីភាពចងក្រងគ្នាជាក្រុមជាពួក ផ្អែកលើអត្តសញ្ញាណវប្បធម៌ និងជាតិសាសន៍។ |
|---|---|
| អត្តសញ្ញាណ | ជាលក្ខណៈសម្បត្តិដែលបុគ្គល ឬក្រុមមនុស្សមានជាគ្រឿងសម្គាល់ផ្ទាល់ខ្លួន។ |
| ភាពអធ្យាស្រ័យ | ការទទួលយកនូវពិពិធភាព។ |

នៅក្នុងរបាយការណ៍របស់ខ្លួនដែលចេញផ្សាយក្នុងឆ្នាំ២០២០ យូអិនឌីភីនិយាយថា អារម្មណ៍អំពីភាពចូលចំណោម ឬនិយាយម៉្យាងទៀតបានថាជា *ជោគវាសនាទូទៅឬរួមដែលមានមូលដ្ឋានលើគុណតម្លៃ ឬកត្តិភាពរួម* ជាសមាសភាគសំខាន់មួយនៅក្នុងសាមគ្គីភាពសង្គម[36]។ នៅក្នុងបរិការណ៍នេះ ភាពចូលចំណោមត្រូវបានកំណត់ន័យថាជាគោលគំនិតនៃការចងក្រងជាក្រុមជាពួក ផ្អែកលើអត្តសញ្ញាណវប្បធម៌ និងជាតិសាសន៍។ ប៉ុន្តែ សំណួរសួរថាតើគេវាស់វែងភាពប្រមូលផ្តុំប្រជាជាតិមួយបានដោយរបៀបណា នៅពេលដែលសមាសភាគពីរ (អត្តសញ្ញាណវប្បធម៌ និង អត្តសញ្ញាណជាតិ) ដែលទ្រទ្រង់ភាពប្រមូលផ្តុំប្រជាជាតិ មានវិសមភាពនឹងគ្នា។ មើលពីជ្រុងមួយ អត្តសញ្ញាណជាតិកម្ពុជាយកខ្មែរជាស្នូលសម្គាល់ខ្លាំងមែនទែន។ ពាក្យថា មោទនភាពជាតិខ្មែរនិងជាតិនិយមខ្មែរ មាននៅសឹងតែគ្រប់ទីកន្លែង តាំងពីឯកសារគោលនយោបាយរដ្ឋាភិបាល រហូតដល់ពាក្យពេចន៍នៅក្នុងបទចម្រៀង។ ប៉ុន្តែបើមើលពីជ្រុងមួយទៀត កម្ពុជាជាប្រទេសមួយមានវប្បធម៌ចម្រុះ ច្រើនបែបជាងអ្វីដែលយើងឃើញស្រាប់ទៅទៀត។ ខ្មែរជាក្រុមពូជសាសន៍ធំជាងគេនៅក្នុងប្រទេសក៏ពិតមែន ប៉ុន្តែមិនមែនមានន័យថាតំណាងឱ្យកម្ពុជាមូលទេ។ កម្ពុជាមានប្រជាជនមកពីជាតិពន្ធុច្រើនក្រុមផ្សេងទៀតកំពុងរស់នៅ (សូមមើលគំនូសតាងទី៣) រួមទាំងក្រុមផ្អែកសង្គមដទៃទៀត មានដូចជាក្រុមស្រលាញ់ភេទដូចគ្នា (LGBTQI+) និងក្រុមជនមានពិការភាព ដែលបានខិតខំតស៊ូមតិទាមទារសិទ្ធិ និងការគិតគូរបែបបរិយាបន្នចំពោះពួកគេផងដែរ។

សរុបមកវិញ ការសន្មត់ថាអារម្មណ៍អំពីភាពចុះសម្រុង មានន័យដូចគ្នានឹងការរួមជោគវាសនាជាមួយគ្នា ហាក់ដូចជាមិនទំនងទេ ព្រោះថា ទម្រង់អត្តសញ្ញាណត្រូវបានរំពឹងថានឹងបន្តប្រែប្រួលទៀត នៅក្នុងបរិបទសង្គមបរិយាបន្ន គ្រាន់តែថាវាប្រែប្រួលច្រើនឬតិចតែប៉ុណ្ណោះ។ ដូច្នេះ អ្វីដែលចោទឡើងនៅទីនេះគឺ តើគួរវាស់វែងភាពចុះសម្រុងគ្នា (togetherness) ដោយរបៀបណា។ តើគួរវាស់វែងតាមរយៈការពិនិត្យមើលថាតើមនុស្សក្រុមផ្សេងៗគ្នានៃប្រជាជាតិមួយរស់នៅរបៀបម៉េច និងអធ្យាស្រ័យចំពោះគ្នាដោយរបៀបណា? ឬដោយពិនិត្យមើលថាតើសង្គមមួយមានពិពិធភាពកម្រិតណា? ចុះគិតយ៉ាងម៉េចទៅវិញ ប្រសិនបើសង្គមមួយមិនសូវមានពិពិធភាព ឬមិនសូវមានបរិយាបន្នទេ ប៉ុន្តែវាមានដំណើរការទៅដោយរលូន? ដូច្នេះ តើភាពចុះសម្រុងក្នុងសង្គមនោះមានកម្រិតណា?

ទាំងអស់នេះជាសំណួរសម្រាប់យើងពិចារណាថា តើអាចចាត់ទុក ភាពចុះសម្រុង ឱ្យស្មើគ្នានិងឯកភាព ដែរឬទេ ឬមួយក៏វាមានជាប់ឫសគល់ជាមួយពាក្យភាពអធ្យាស្រ័យ ដែលត្រូវបានកំណត់និយមន័យថាជាការទទួលយក "ភាពដទៃ" និងភាពខុសៗគ្នា។

ជាថ្មីម្តងទៀត ចំណុចសំខាន់ដែលត្រូវបញ្ជាក់ឡើងវិញគឺ ការឱ្យនិយមន័យពាក្យ "unity" ជាភាសាខ្មែរ មិនមែនជារឿងសាមញ្ញទេ។ ឧបករណ៍ប្រែសម្រួល Google ប្រែពាក្យ unity ថា "រួបរួមជាតិ" ប៉ុន្តែ ដូចបានរៀបរាប់នៅខាងលើក្នុងរបាយការណ៍នេះ គឺពាក្យ "សាមគ្គីភាព" ទៅវិញ ដែលតែងត្រូវបានប្រើក្នុងការកំណត់និយមន័យពាក្យ unity។ ការធ្វើបែបនេះនាំឱ្យមានភាពច្របូកច្របល់ ព្រោះថាពាក្យ

“សាមគ្គីភាព” ត្រូវនឹងពាក្យ “solidarity” ជាភាសាអង់គ្លេស។ ហេតុនេះ ពាក្យថា ឯកភាព unity ដែលចេញពីមាត់រដ្ឋាភិបាល ប្រហែលជាមិនអាចប្រែក្នុងន័យ unity ដែលសំដៅការរួមចំណែកដល់សាមគ្គីភាពសង្គមបែបធម្មជាតិ ដែលរបាយការណ៍នេះព្យាយាមសិក្សាស្វែងយល់។ ចំណែកឯនិយមន័យរបស់ភាពចូលចំណោម គឺសំដៅលើសតិអំពីភាពចុះសម្រុងគ្នា ឬ អំពីភាពស្និទ្ធស្នាលបែបធម្មជាតិក្នុងចំណោមបុគ្គល ឬក្រុមច្រើនផ្សេងៗគ្នានៅក្នុងសង្គមមួយ។

សម្រាប់បរិបទកម្ពុជា កាលណាពិនិត្យមើលសតិអំពីភាពចុះសម្រុងរបស់ពលរដ្ឋ គេគួរចាប់ផ្តើមស្វែងយល់អំពីអត្តសញ្ញាណជាតិ និងវប្បធម៌ មុនគេ។

***អត្តសញ្ញាណ*** សំដៅលើលក្ខណៈសម្បត្តិដែលបុគ្គល ឬ ក្រុមមនុស្សមានជាគ្រឿងសម្គាល់ផ្ទាល់ខ្លួន។ វាជាអនុវិមាត្រមួយសម្រាប់ការសិក្សាស្វែងយល់ និងរៀបចំម៉ូដែល។ ដូចត្រូវបានលើកឡើងនៅខាងលើ ជនជាតិកម្ពុជាមានជាប់ជិតដាមដោយស្នាមរបួសពីសោកនាដកម្ម និងការវិនាសបាត់បង់នៅក្នុងសម័យខ្មែរក្រហម។ ឯកសារសិក្សាស្រាវជ្រាវជាច្រើនបានសរសេរស្មារតីចងចាំរួមរបស់កម្ពុជា ភ្ជាប់ជាមួយនឹងការចោទសួរដេញដោលទៅលើសតិអំពីភាពចូលចំណោម ក្រោមស្រមោលនៃអំពើប្រល័យពូជសាសន៍នៃរបបខ្មែរក្រហម។ នៅកម្ពុជានាពេលបច្ចុប្បន្ន អត្តសញ្ញាណជាតិលេចធ្លោសំខាន់ៗ សុទ្ធតែជិតដាមដោយភាពឈឺចាប់គ្រាំគ្រា ដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម[37]។ ជាទូទៅ ប្រជាជនកម្ពុជាដឹងថាមានរបបខ្មែរក្រហម និងការបំផ្លិចបំផ្លាញហិនហោចដែលរបបនេះបានបន្សល់ទុក។ ថ្ងៃជ័យជំនះ៧មករា ដែលត្រូវបានប្រារព្ធធ្វើរៀងរាល់ឆ្នាំ ត្រូវបានរដ្ឋាភិបាលកាន់អំណាចបច្ចុប្បន្ន កំណត់ជាយុទ្ធសាស្ត្រថាជាថ្ងៃកំណើតទីពីររបស់ប្រជាជនកម្ពុជា។ ជាងសែសិបឆ្នាំកន្លងផុតទៅក៏ពិតមែន ប៉ុន្តែស្មារតីកសាងជាតិឡើងវិញពីចំណុចសូន្យ ត្រូវបានរដ្ឋាភិបាលធ្វើការស្រោចស្រពឥតឈប់ឈរទៅលើប្រជាជន មកដល់សព្វថ្ងៃ។ យ៉ាងណាក៏ដោយ ភាពខុសគ្នាពីមួយជំនាន់ទៅមួយជំនាន់ បានធ្វើឱ្យមានចរន្តដាកចេញបន្តិចម្តងៗពីអត្តសញ្ញាណដែលធ្លាប់តែជិតដាមដោយស្នាមរបួសគ្រាំគ្រាពីអតីតកាល។ ភាពតានតឹងកំពុងកើតមានរវាងយុវជនកម្ពុជា ដែលព្យាយាមបង្កើតអត្តសញ្ញាណជាតិថ្មីមួយមានភាពសម្បូរបែបហើយឆ្លុះបញ្ចាំងគុណតម្លៃរបស់ពួកគេ និងមនុស្សជំនាន់មុនដែលប្រកាន់ខ្ជាប់នូវប្រពៃណីបុរាណ និងក្តោបក្តាប់អំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ បើទោះជាមិនមានការជជែកដេញដោលនៅក្នុងស្រុកជាសាធារណៈអំពីអត្តសញ្ញាណជាតិក៏ដោយ ក៏គេសង្កេតឃើញថាមានចរន្តពង្រឹងស្មារតីអំពីអត្តសញ្ញាណខ្មែរកាន់តែខ្លាំងឡើងៗ តាមរយៈសកម្មភាពនានាដែលផ្តួចផ្តើមគំនិតរៀបចំដោយរដ្ឋាភិបាល។ ឧទាហរណ៍ កម្ពុជាមានកំណត់ត្រាឯកទគ្គកម្មបីមុខនៅក្នុងសៀវភៅ Guinness Book ក្រមាត្បាញវែង, ទូកងវែង និងនំអន្សមវែងជាងគេលើពិភពលោក។ ប្រធានបទនីមួយៗដណ្តើមបានកំណត់ត្រាឯកទគ្គកម្ម តាមរយៈកម្មវិធីដែលផ្តួចផ្តើមគំនិតដោយអង្គការយុវជនជ្រកក្រោមដំបូលរដ្ឋាភិបាល ដែលខិតខំបញ្ជ្រាបស្មារតីមោទនភាពជាតិ និងរំលេចអំពីវប្បធម៌ខ្មែរ។ ត្រង់នេះគួរបញ្ជាក់ដែរថា ខ្មែរគ្រាន់តែពូជសាសន៍មួយក្រុមប៉ុណ្ណោះក្នុងចំណោមពូជសាសន៍ច្រើនក្រុមទៀតដែលបង្កើតបានជាសញ្ជាតិកម្ពុជា។

ពាក្យ “កម្ពុជា” និង “ខ្មែរ” ត្រូវបានគេប្រើឆ្លាស់គ្នាគ្រប់កាលៈទេសៈ។ ប៉ុន្តែ ពាក្យទាំងនេះមិនបានឆ្លុះបញ្ចាំងសព្វគ្រប់អំពីសមាសភាគផ្សេងទៀតនៅកម្ពុជាទេ ក្នុងនោះមាន ជនជាតិវៀតណាម ចាម និងក្រុមជនជាតិដើមភាគតិច ដែលខ្លះមានភាសាដើមរបស់ខ្លួនទៀតផង[38]។

[37] Din, D. (2020). Cambodian Identity, Culture and Legacy. In S. Deth, B. Murg, V. Ou & M. Renfrew, Cambodia 2040: Culture and Society. Phnom Penh: Konrad-Adenauer-Stiftung, Cambodia and Future Forum.

[38] Ethnic minorities and indigenous people | Open Development Cambodia (ODC). (2016). Retrieved 7 November 2021, from https://opendevelopmentcambodia.net/topics/ethnic-minorities-and-indigenous-people/#ref-95458-1

**គំនូសតាង ៣៖ ផែនទីស្ដីពីប្រជាជនជាជនជាតិដើមភាគតិចនៅកម្ពុជា[39]**

ទន្ទឹមនឹងការដែលមានវប្បធម៌, ពូជពង្ស និងសាសនាចម្រុះ កម្ពុជានៅបន្តអភិវឌ្ឍអត្តសញ្ញាណរបស់




ខ្លួន គឺអត្តសញ្ញាណខ្មែរអ្នកកាន់ពុទ្ធសាសនាភាគច្រើនលើសលប់។ ខ្មែរជាភាសាផ្លូវការ ហើយក៏ជាភាសាតែមួយដែលប្រើប្រាស់នៅក្នុងការបង្រៀននៅតាមសាលាភាគច្រើនក្នុងប្រព័ន្ធអប់រំសាធារណៈ។ ប្រការដែលគួរឱ្យលើកទឹកចិត្តគឺកន្លងមកមានការប្រឹងប្រែងច្រើនក្នុងការផ្ដល់កម្មវិធីសិក្សាជាប្រាំភាសារបស់ក្រុមជនជាតិដើមភាគតិច (ដូចជាភាសាព្នង ការវេត គ្រឹង តាំពួន និងព្រៅ)។ កម្មវិធីសិក្សាទាំងនោះបានយកទៅអនុវត្តក្រោយពីរដ្ឋាភិបាល នៅឆ្នាំ២០១៥ បានដាក់ចេញនូវផែនការសកម្មភាពអប់រំជាតិពហុភាសា ឆ្នាំ២០១៤-២០១៨ (Multilingual Education National Action Plan/MENAP)[40]។ ផែនការសកម្មភាពនោះមានវិសាលភាពអនុវត្តទៅលើខេត្តមណ្ឌលគិរី, រតនគិរី និងស្ទឹងត្រែង និងក្រុមកុមារជនជាតិដើមភាគតិចមួយចំនួន តែប៉ុណ្ណោះ។

ដោយសារវប្បធម៌ និង អត្តសញ្ញាណប្រទាក់ក្រឡាចាក់ស្រេះជាមួយគ្នា ភាពគ្រប់ដណ្ដប់លើសលប់នៃអត្តសញ្ញាណខ្មែរក៏ជាកត្តាដើរតួកំណត់អានុភាពនៃជវភាពផ្នែកវប្បធម៌របស់កម្ពុជាដែរ។ វប្បធម៌ខ្មែរត្រូវបានរំលេចធ្វើជាឧបករណ៍សម្រាប់អនុវត្តន៍តាមរយៈគោលនយោបាយវប្បធម៌ជាតិកម្ពុជា (Cambodia's National Policy for Culture)[41]។ វត្តមានលើសលប់នៃអត្តសញ្ញាណខ្មែរអាចត្រូវបានយកទៅ

---

[39] Open Development Cambodia (2016)

[40] Evaluation of the Multilingual Education National Action Plan in Cambodia. (2019). Retrieved 19 November 2021, from https://www.unicef.org/cambodia/reports/evaluation-multilingual-education-national-action-plan-cambodia

[41] National Policy for Culture, 2014.

ប្រើប្រាស់ ក្នុងការឃោសនាគំនិតបំភាន់ថា កម្ពុជាមានសាមគ្គីភាពសង្គមក្នុងសង្គម។ អាស្រ័យហេតុនេះ សំខាន់ណាស់ដែលត្រូវធានាយ៉ាងណាឱ្យភាពស្និទ្ធស្នាលសង្គម នៅក្នុងឌីណាមិកនៃភាពចូលចំណោមក្នុងបរិបទកម្ពុជា ក្ដាប់បាននូវតថភាពជាក់ស្ដែងរបស់ក្រុមប្រជាជនដែលមិនសូវមានគេរវីរវល់ជាមួយ និងងាយរងគ្រោះ។ តថភាពដែលមិនអាចប្រកែកបានមានដូចជា ការរឹបអូសយកដីធ្លីពីជនជាតិដើមភាគតិច ដែលភាសានិងវប្បធម៌របស់ខ្លួនត្រូវបានគេមើលរំលង គ្មានអ្នកណាអើពើជាមួយ និងគ្មានការអភិរក្សថែរក្សា។ របាយការណ៍សិទ្ធិមនុស្សមួយដែលមានចំណងជើងជាអង់គ្លេសថា The 3rd Cycle of Universal Periodic Review of Cambodia on “Situation of Indigenous Peoples in Cambodia” សម្រាប់ខែមករា និង កុម្ភៈ ឆ្នាំ២០១៩ បានរំលេចនូវបញ្ហាប្រឈមធំៗដែលសហគមន៍ជនជាតិដើមភាគតិចកំពុងជួបប្រទះ មានដូចជាអវត្តមាននូវការទទួលស្គាល់ចំពោះទំនាក់ទំនងរបស់ជនជាតិដើមភាគតិចជាមួយដីធ្លី ដែនដី និងធនធានធម្មជាតិ។ ថ្វីដ្បិតតែពួកគេមានភាសារបស់ខ្លួនក៏ពិតមែន ប៉ុន្តែមនុស្សជាច្រើនក្នុងចំណោមពួកគេលែងចេះនិយាយភាសាកំណើតរបស់ខ្លួនហើយ ដោយសារតែការរើសអើង និងកង្វះការទទួលស្គាល់ផ្នែកច្បាប់[42]។ ប្រជាជនជាជនជាតិដើមភាគតិចនៅកម្ពុជាក៏បាត់ផងដែរនូវសិទ្ធិកាន់កាប់ដីធ្លី តាមរយៈការធ្វើសម្បទានដីធ្លី ជម្លោះដីធ្លី កំណើនដីធ្លី និងចំណាកស្រុកចូលពីតំបន់ផ្សេង ខណៈដែលការបំផ្លាញព្រៃឈើបានបង្កផលប៉ះពាល់ខ្លាំងទៅលើការចិញ្ចឹមជីវិតរបស់ពួកគេ[43]។

ការសិក្សាទៅលើ ***ភាពអធ្យាស្រ័យ*** គឺជាអនុវិមាត្រមួយទៀតសំខាន់ សម្រាប់ពិចារណាអំពីភាពចូលចំណោម។ ភាពអធ្យាស្រ័យ មានន័យសំដៅការទទួលយកពិពិធភាព ហើយមានទំនាក់ទំនងទៅនឹងមនោសញ្ចេតនាទូទៅ និងក្នុងចំណោមមនុស្សក្នុងក្រុមដូចគ្នា ចំពោះអ្នកដទៃ។ ការពិភាក្សាបែបប្រពៃណីអំពីភាពអធ្យាស្រ័យ នឹងពិចារណាទៅលើឥរិយាបថចំពោះយេនឌ័រ ភេទ និងក្រុមជាតិសាសន៍។ ដោយពិចារណាលើអតុល្យភាពក្នុងសង្គមកម្ពុជាក្នុងបរិបទអត្តសញ្ញាណ និងវប្បធម៌ អនុវិមាត្រនានាជុំវិញភាពចូលចំណោម ***(belonging)*** ផ្ដោតទៅលើការសម្របសម្រួលចំណេះដឹងជុំវិញភាពចាំបាច់លើកកម្ពស់អត្តសញ្ញាណ និងវប្បធម៌រួម ដែលមានភាពបរិយាបន្នកាន់តែប្រសើរឡើងនៅកម្ពុជា។ អ្វីដែលគួរមានទូលំទូលាយ គឺ “ភាពសុខដុម” ជាជាងការផ្ដោតគំនិតតែទៅលើពាក្យរួបរួម។ សូចនាករគំរូមាននៅក្នុងតារាងវិមាត្រទី២។

[42] Situation of Indigenous Peoples in Cambodia. (2019). In 3rd Cycle of Universal Periodic Review of Cambodia, 32nd Session of the Human Rights Council. Retrieved from https://www.upr-info.org/sites/default/files/document/cambodia/session_32_-_january_2019/js1_upr32_khm_e_main.pdf

[43] Ibid.

## វិមាត្រទី ៣៖ បរិយាបន្ន

| | |
|---|---|
| **បរិយាបន្ន** | សំដៅលើវិសាលភាពដែលមនុស្សម្នាក់មានសម្រាប់ការចូលរួមនានានៅក្នុងសង្គម ដោយគ្មានការភ័យខ្លាចចំពោះការរើសអើង, ការផាត់ចេញ ឬការបង្ខំ ណាមួយ។ |
| សេដ្ឋកិច្ច | តំណាងដោយសូចនាករស្ដីពីការចូលរួមផ្នែកសេដ្ឋកិច្ច និងការធ្វើសេចក្ដីសម្រេចនានា។ |
| នយោបាយ | តំណាងដោយការចូលរួមស្មើភាពនិងយ៉ាងសកម្មរបស់ប្រជាជននៅក្នុងវិស័យនយោបាយ។ |
| សង្គម | តំណាងដោយដំណើរការកែលម្អឱ្យប្រសើរនូវលក្ខខណ្ឌនានា សម្រាប់ការចូលរួមរបស់បុគ្គលឬក្រុម នៅក្នុងសង្គម។ |

បរិយាបន្ន គឺជាទំហំលទ្ធភាពដែលមនុស្សម្នាក់មានសម្រាប់ការចូលរួមនានានៅក្នុងសង្គម ដោយគ្មានការភ័យខ្លាចចំពោះការរើសអើង ការផាត់ចេញ ឬការបង្ខំ ណាមួយ។ វាមានអនុវិមាត្របី ដែលនឹងលើកយកមកពិភាក្សានៅខាងក្រោម។ បរិយាបន្ន នៅក្នុងបរិបទនេះ ចង់និយាយអំពី បរិយាបន្ន ឬ គ្មានបរិយាបន្ន ផ្អែកលើអត្តសញ្ញាណ[44]។ ខណៈដែលភាពចូលចំណោមក្នុងប្រជាជាតិមួយមានឬសគល់ជ្រៅជាមួយភាពអធ្យាស្រ័យចំពោះពិពិធភាព បរិយាបន្នគឺជាជម្រើសរបស់បុគ្គល មិនមែនជាកាតព្វកិច្ចទេ។

នៅកម្ពុជា អារម្មណ៍អំពីភាពបរិយាបន្ន ច្រើនតែច្របូកច្របល់ជាមួយការសន្និដ្ឋានថា ជនកម្ពុជាទាំងអស់គឺជាខ្មែរ។ ដូចត្រូវបានលើកឡើងរួចមកហើយ ពាក្យ “ខ្មែរ” សំដៅលើចំណាត់ប្រភេទជាតិសាសន៍នៅក្នុងចំណោមជាតិសាសន៍នានាដែលបង្កើតបានជាប្រជាជនកម្ពុជា។ ពាក្យនេះមិនមែនជាលក្ខណៈវិនិច្ឆ័យរួមទេ ព្រោះថា ពលរដ្ឋកម្ពុជាអាចសំដៅទៅលើក្រុមណាមួយក្នុងចំណោមក្រុមជាតិសាសន៍នានា ដែលរស់នៅក្នុងព្រះរាជាណាចក្រនេះ។ សារៈសំខាន់នៃការគូសរំលេចចំណុចនេះ គឺនៅត្រង់អារម្មណ៍អំពីភាពទីទៃ (sense of otherness) ដែលគេអាចសង្កេតឃើញមាននៅក្នុងសង្គមកម្ពុជា។ ឧទាហរណ៍ តាមការសង្កេតទូទៅ កាលណាជនកម្ពុជាមានដើមកំណើតជាខ្មែរលើកឡើងអំពីជនកម្ពុជាម្នាក់ណាផ្សេងដែលមិនមានដើមជាខ្មែរ គេតែងតែនិយាយដោយភ្ជាប់ជាមួយអត្តសញ្ញាណជាតិសាសន៍របស់អ្នកនោះ ដូចជា ចាម ចិន ឬវៀតណាម។

អត្តសញ្ញាណជាតិសាសន៍ គឺជាចំណាត់ថ្នាក់តែមួយដែលជាប្រភពនៃការកើតមានបញ្ហាជុំវិញបរិយាបន្ន ហើយត្រង់នេះវាពិតសម្រាប់វិមាត្រទាំងអស់របស់សាមគ្គីភាពសង្គម។ កត្តាសង្គម និងសេដ្ឋកិច្ច និងស្ថានភាពប្រជាសាស្ត្រ ជាចំណុចប្រសព្វសម្រាប់បញ្ហានៃ “ភាពទីទៃ”។ លក្ខណៈសម្បត្តិរបស់អត្តសញ្ញាណយេនឌ័រ ស្ថានភាពអាពាហ៍ពិពាហ៍ ឬស្ថានភាពប្រាក់ចំណូលរបស់ប្រជាជាតិមួយអាចនាំមកនូវសតិមួយអំពីភាពបរិយាបន្ន និង ភាពអធ្យាស្រ័យ ឬមួយក៏អាចនាំឱ្យមានសតិអំពីអសុខដុមភាព ក៏ថាបាន។

របាយការណ៍នេះពិនិត្យមើលបរិយាបន្នតាមរយៈអនុវិមាត្របី ក្នុងនោះមានសូចនាករពាក់ព័ន្ធការចូលរួមផ្នែកសេដ្ឋកិច្ច និងក្នុងការធ្វើសេចក្ដីសម្រេច ដើម្បីបរិយាបន្នសេដ្ឋកិច្ច បរិយាបន្ននយោបាយ និងបរិយាបន្នសង្គម។

***បរិយាបន្នសេដ្ឋកិច្ច៖*** នៅក្នុងនេះមានកម្រិតប្រាក់ចំណូល កម្មសិទ្ធិអាជីវកម្ម និងកម្មសិទ្ធិដីធ្លី។ វិសមធម៌ក្នុងការទទួលបានផលសេដ្ឋកិច្ច អាចនាំឱ្យមាននូវវិសមធម៌ក្នុងសាមគ្គីភាពសង្គម, អស្ថិរភាពនយោបាយ, និងប៉ះពាល់ដល់សន្តិភាពជាតិ។

[44] UNDP (2020). Strengthening Social Cohesion: Conceptual Framing and Programming Implications, UNDP.

យោងតាម The Rockefeller Foundation[45] បរិយាបន្នសេដ្ឋកិច្ចសំដៅលើការពង្រីកកាលានុវត្តភាពសម្រាប់ឈានទៅសម្រេចបានវិបុលភាពរួមកាន់តែទូលំទូលាយ ជាពិសេសសម្រាប់ក្រុមប្រជាជនដែលជួបឧបសគ្គច្រើនក្នុងកិច្ចខិតខំបង្កើនសុខុមាលភាពរបស់ខ្លួន។ មានលក្ខណៈសម្បត្តិទូទៅចំនួនប្រាំសម្រាប់យកមកពិចារណាអំពីបរិយាបន្នផ្នែកសេដ្ឋកិច្ចៈ

១. ***សមធម៌៖*** សំដៅលើកាលៈទេសៈដែលមានកាលានុវត្តភាពកាន់តែច្រើន ដើម្បីបង្កលក្ខណៈឱ្យមនុស្សកាន់តែច្រើនឈានទៅរកវឌ្ឍនភាព។ គ្រប់ស្រទាប់សង្គម ជាពិសេស ជនក្រីក្រ ឬក្រុមជនងាយរងគ្រោះ អាចទាញយកចំណេញពីកាលានុវត្តភាពទាំងនេះបាន។ វិសមភាពកំពុងតែធ្លាក់ចុះ ប្រជាជនក៏មានលទ្ធភាពស្មើភាពទទួលបានគ្រឹះសេដ្ឋកិច្ចរឹងមាំ រួមទាំងលទ្ធភាពស្មើភាពក្នុងការទទួលបានអត្ថប្រយោជន៍ សេវា និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់គ្រាន់ មានដូចជាមធ្យោបាយដឹកជញ្ជូនសាធារណៈ ការអប់រំ ខ្យល់បរិសុទ្ធ និងទឹក។

២. ***ការចូលរួម៖*** ប្រជាជនអាចចូលរួមពេញទំហឹងនៅក្នុងជីវភាពសេដ្ឋកិច្ច និងមានសេរីភាពបញ្ចេញយោបល់កាន់តែច្រើនអំពីអនាគតរបស់ពួកគេ។ ប្រជាជនមានលទ្ធភាពចូលរួមក្នុងសកម្មភាពទីផ្សារ ក្នុងភាពជាពលករ អ្នកប្រើប្រាស់ និងម្ចាស់អាជីវកម្ម។ តម្លាភាព និងចំណេះដឹងទូទៅអំពីវិធាននិងបទដ្ឋាននានា បានបង្កលទ្ធភាពឱ្យប្រជាជនអាចបើកអាជីវកម្ម រកការងារធ្វើ ឬចូលប្រឡូកផ្ទាល់ក្នុងទីផ្សារ។ បច្ចេកវិទ្យាមានការសាយភាយកាន់តែទូលំទូលាយ ជួយលើកកម្ពស់ឱកាសសម្រាប់បុគ្គល និងសហគមន៍សម្រាប់ឈានទៅមានសុខុមាលភាពកាន់តែប្រសើរ។

៣. ***កំណើន៖*** សេដ្ឋកិច្ចមានសមត្ថភាពផលិតទំនិញនិងសេវាគ្រប់គ្រាន់បានកាន់តែច្រើន ផ្តល់ប្រយោជន៍កាន់តែធំធេងដល់សុខុមាលភាព និងឱកាសនានា។ ការងារល្អៗ និងឱកាសការងារកាន់តែសម្បូរ ប្រាក់ចំណូលក៏កើន ជាពិសេសសម្រាប់ជនក្រីក្រ។ ប្រព័ន្ធសេដ្ឋកិច្ចកំពុងមានការផ្លាស់ប្តូរជាបន្តបន្ទាប់ដើម្បីធ្វើឱ្យមានភាពកាន់តែប្រសើរឡើងដល់ជីវភាពសម្រាប់ទាំងអស់គ្នា ជាពិសេសជនក្រីក្រ និងសហគមន៍ដែលមិនសូវមានគេរវីរវល់ជាមួយកន្លងមក។ កំណើនសេដ្ឋកិច្ចនិងការធ្វើអន្តរកម្មផ្លាស់ប្តូរមិនសំដៅតែទៅលើការវាស់វែងផលសេដ្ឋកិច្ចតាមរយៈផ.ស.សម្មួយមុខទេ ប៉ុន្តែត្រូវបញ្ចូលសូចនាករផលសេដ្ឋកិច្ចផ្សេងទៀតពាក់ព័ន្ធនឹងសុខុមាលភាព ផងដែរ។

៤. ***ចីរភាព៖*** ធនធានសេដ្ឋកិច្ចនិងសង្គមរក្សាបានយូរអង្វែង ជាប្រយោជន៍ដល់សុខុមាលភាពរបស់ប្រជាជនពីមួយជំនាន់ទៅមួយជំនាន់។ ក្នុងករណីមូលធនធម្មជាតិ សេដ្ឋកិច្ចប្រកបដោយបរិយាបន្នគឺជាសេដ្ឋកិច្ចដែលថែរក្សាឬស្តារឡើងវិញនូវសមត្ថភាពរបស់ធម្មជាតិ ក្នុងការផលិតទំនិញនិងសេវារបស់ប្រព័ន្ធអេកូឡូស៊ី ដែលមានប្រយោជន៍ដល់សុខុមាលភាពរបស់មនុស្ស អមជាមួយនឹងការធ្វើសេចក្តីសម្រេចដែលគិតគូរបញ្ចូលនូវចំណាយនិងផលចំណេញយូរអង្វែង ជាជាងគ្រាន់តែសំឡឹងលើការទាញយកផលចំណេញពីសម្បត្តិជាមូលដ្ឋានសេដ្ឋកិច្ចសម្រាប់រយៈពេលខ្លី។

៥. ***ស្ថិរភាព៖*** បុគ្គល សហគមន៍ ធុរកិច្ច និងរដ្ឋាភិបាលមានភាពជឿជាក់គ្រប់គ្រាន់អំពីអនាគត និងលទ្ធភាពប្រសើរជាងមុន សម្រាប់ព្យាករផលដែលអាចកើតចេញពីការធ្វើសេចក្តីសម្រេចផ្នែកសេដ្ឋកិច្ច។ បុគ្គល ក្រុមគ្រួសារ សហគមន៍ និងបណ្តាក្រុមហ៊ុន មានសន្តិសុខគ្រប់គ្រាន់សម្រាប់ការវិនិយោគរបស់គេទៅថ្ងៃអនាគត។ ប្រព័ន្ធសេដ្ឋកិច្ចកាន់តែមានភាពធន់សម្រាប់ទប់ទល់នឹងស្ថានភាពធក់កន្ត្រាក់ ឬភាពតឹងផ្នែកសេដ្ឋកិច្ច ជាពិសេសព្រឹត្តិការណ៍បន្ទុចបង្អាក់នានា ដែលអាចបង្កផលប៉ះទង្គិចហួសប្រមាណមកលើសហគមន៍ជនក្រីក្រ និងជនងាយរងគ្រោះ។

និយមន័យនេះរួមបញ្ចូលគោលការណ៍ស្តីពីកំណើនប្រកបដោយបរិយាបន្ន ដែលក្នុងនោះផ្តោតសំខាន់ទៅលើការធ្វើយ៉ាងណាឱ្យសមាជិកទាំងអស់ក្នុងសង្គមមួយ មានលទ្ធភាពរួមចំណែកដល់ និងទទួលផលពីកំណើនសេដ្ឋកិច្ច ប៉ុន្តែជាមួយគ្នានោះគោលការណ៍នោះក៏ពិនិត្យមើលថាតើមានកត្តាអ្វីខ្លះដែលនាំឱ្យខាតទៅវិញ។

---

[45] The Rockefeller Foundation (2016), Inclusive Economy Indicators.

ពីរទសវត្ស៍នៃការប្រែប្រួលបានធ្វើឱ្យកម្ពុជាដណ្តើមបានឋានៈជាប្រទេសមានចំណូលទាបមធ្យម អមដោយមហិច្ឆិតាក្លាយជាប្រទេសមានចំណូលខ្ពស់មធ្យមនៅឆ្នាំ២០៣០។ វណ្ណៈកណ្តាលមួយកំពុងតែលេចរូបរាងឡើងនៅក្នុងដំណាក់កាលបន្ទាប់មកទៀតនៃសេដ្ឋកិច្ចទាំងវិបុលភាព និងវិសមភាព។ ដូចមានបង្ហាញនៅក្នុងតារាងសូចនាករខាងក្រោម បរិយាបន្ននៃសេដ្ឋកិច្ចរាប់បញ្ចូលនូវចលនានានានៃសេដ្ឋកិច្ច ក្នុងទិដ្ឋភាពប្រាក់ចំណូល ការអប់រំ សុខាភិបាល អាហារូបត្ថម្ភ និងលទ្ធភាពទទួលបានបច្ចេកវិទ្យា។

***បរិយាបន្ននយោបាយ*** ប្រហែលជាវិមាត្រមួយមានភាពរសើបជាងគេនៅក្នុងរបាយការណ៍នេះ។ វាមានន័យសំដៅលើការចូលរួមស្មើភាពនិងយ៉ាងសកម្មរបស់ប្រជាជន នៅក្នុងវិស័យនយោបាយ។

ដូចបានដឹងស្រាប់ ប្រព័ន្ធនយោបាយរបស់កម្ពុជា បានស្ថិតក្រោមភាពលប់លើរបស់គណបក្សប្រជាជនកម្ពុជាអស់ជាងបីទសវត្សរ៍មកហើយ[46]។ ដំណើរវិវត្តន៍យ៉ាងលឿនរបស់កម្ពុជាក្លាយទៅជារដ្ឋដែលមានការប្រមូលផ្តុំអំណាចឯកបក្សរឹងមាំ គឺជាផ្នែកមួយនៃការប្រែប្រួលរបៀបរបបសេរីនិយមលើផ្ទៃអន្តរជាតិ នៅក្រោយសម័យសង្គ្រាមត្រជាក់[47]។ ភាពស្របច្បាប់របស់គណបក្សមានមូលដ្ឋានលើសមត្ថភាពរបស់ខ្លួនក្នុងការបំពេញបានតាមការសន្យាថានាំមកនូវស្ថិរភាព និងវិបុលភាពជូនប្រទេស[48] ដែលជាកត្តាចម្បងជួយឱ្យកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងលឿនពេញមួយសតវត្សរ៍ទី២១។ ប៉ុន្តែ ស្ថិរភាពនិងវិបុលភាពនេះមានអមដោយពាក្យចោទប្រកាន់អំពីអំពើពុករលួយ, ការនិយមញាតិសន្តាន និងការរឹតត្បិតលំហសេរីភាពស៊ីវិល[49]។ ឧទាហរណ៍ពាក់ព័ន្ធការចោទប្រកាន់ទាំងនោះមានច្រើន រួមទាំងការរំលាយគណបក្សសង្គ្រោះជាតិកម្ពុជា[50] ការចោទប្រកាន់ឡើងតុលាការនូវសកម្មជនគណបក្សប្រឆាំងនិងសិទ្ធិមនុស្ស[51] និងការបិទអង្គភាពសារព័ត៌មានមួយចំនួន[52]។

បើមើលពីជ្រុងទស្សនៈសញ្ជាតិ ពាក្យថាបរិយាបន្នសឹងតែមិនដែលឮទេក្នុងស្រទាប់ពលរដ្ឋជនជាតិដើមភាគតិចនៅកម្ពុជា ក្រៅពីពរដ្ឋមានដើមកំណើតជាខ្មែរ។ ការចូលរួមពីសំណាក់ក្រុមជនជាតិដើមភាគតិចនៅក្នុងវិស័យនយោបាយកម្រមានគេលើកយកមកជជែកណាស់ ហើយផ្នត់គំនិតអវិជ្ជមានចំពោះក្រុមជនជាតិភាគតិចមួយចំនួន ត្រូវបានគេយកទៅធ្វើអាជីវកម្មជាឧបករណ៍នយោបាយ។ ឧទាហរណ៍ជាក់ស្តែង គឺមនោសញ្ចេតនាមិនចូលចិត្តចំពោះជនជាតិវៀតណាម ដែលអ្នកនយោបាយខ្លះយកមកប្រើប្រាស់សម្រាប់ស្វែងរកប្រជាប្រិយភាព[53]។ ការណ៍ដែលប្រទេសជិតខាងមិនចូលចិត្តគ្នាមិនមែនជារឿងចម្លែកទេ ប៉ុន្តែមនោសញ្ចេតនាប្រឆាំងជនជាតិវៀតណាម បានលាតត្រដាងឱ្យឃើញនូវគន្លងពឹងពាក់គ្នាទៅវិញទៅមកយ៉ាងមាំទាំ កាលណាគេមើលពីជ្រុងទស្សនៈស្តីពីភាពសាមគ្គីភាពសង្គម។ ក្រៅពីនៅជាលេសនយោបាយសម្រាប់ការតទល់គ្នារវាងគណបក្សកាន់អំណាច និងក្រុមប្រឆាំង ជនជាតិវៀតណាមត្រូវបានគេផាត់ចេញពីដំណើរការនយោបាយទាំងស្រុង[54]។ ទិដ្ឋ

---

[46] Freedom House (2021) https://freedomhouse.org/country/cambodia/freedom-world/2021

[47] J. Ikenberry (2018), *The End of Liberal International Order?*, International Affairs 94(1): 7–23.

[48] K. Travouillon (2021), *From “Sphere of Scrutiny” to “Sphere of Opportunity”,* Contemporary Southeast Asia, 43(2): 370-394.

[49] Markus Karbaum (2021), *Cambodia’s Leadership Succession: One small Step Further*, The Diplomat.

[50] Ben, S., Mech, D., & Baliga, A. (2017). ‘Death of democracy’: CNRP dissolved by Supreme Court ruling. The Phnom Penh Post. Retrieved from https://www.phnompenhpost.com/national-post-depth-politics/death-democracy-cnrp-dissolved-supreme-court-ruling

[51] Khy, S. (2021). Four environment activists arrested and accused of plotting, according to NGO. Cambojanews. Retrieved from https://cambojanews.com/four-environment-activists-arrested-and-accused-of-plotting-according-to-ngo/

[52] https://www.ifj.org/actions/ifj-campaigns/charting-cambodias-declining-press-freedom.html

[53] Willemyns, A. (2017). CNRP clings to anti-Vietnamese rhetoric. The Phnom Penh Post. Retrieved from https://www.phnompenhpost.com/national/cnrp-clings-anti-vietnamese-rhetoric

[54] Cambodia: Freedom in the World 2020 Country Report | Freedom House. (2022). Retrieved 15 January 2022, from https://freedomhouse.org/country/cambodia/freedom-world/2020

ភាពមួយទៀតជុំវិញការមិនរាប់បញ្ចូលក្នុងដំណើរការនានា គឺបញ្ហានៃការចូលរួមរបស់ស្ត្រីក្នុងថ្នាក់ដឹកនាំនយោបាយនៅកម្ពុជា។ គិតត្រឹមឆ្នាំ២០២២ ស្ត្រីមានចំនួនតែ១៥ភាគរយប៉ុណ្ណោះក្នុងចំណោមសមាជិករដ្ឋសភា[55]។ ហេតុនេះ គេអាចពិនិត្យមើលថាតើប្រជាជនកម្ពុជាអាចសុខចិត្តទ្រាំបានប៉ុនណា ជាមួយនឹងការធ្លាក់ចុះនៃសិទ្ធិ និងការបាត់បង់សេរីភាពក្នុងការបញ្ចេញមតិ និងការរិះគន់ ជាដើម។

ដើម្បីយល់ឱ្យបានកាន់តែប្រសើរថែមទៀតអំពីទិដ្ឋភាពបរិយាបន្ននយោបាយនៅកម្ពុជា អនុវិមាត្រនេះនឹងពិនិត្យមើលទៅលើភាពជាតំណាង និងការចូលរួម។

***បរិយាបន្នសង្គម៖*** បរិយាបន្នសង្គមតំណាងដោយដំណើរការកែលម្អឱ្យប្រសើរនូវលក្ខខណ្ឌនានា សម្រាប់ការចូលរួមរបស់បុគ្គលឬក្រុម នៅក្នុងសង្គម។

មានទិដ្ឋភាពច្រើនដែលគួរសិក្សាស្រាវជ្រាវមើលនៅក្នុងសង្គម។ ទីមួយ មានការបែងចែកស្រទាប់វណ្ណៈកាន់តែច្រើនឡើងនៅក្នុងសង្គមកម្ពុជា។ អ្នកមានមានជីវភាពកាន់តែស្ដុកស្ដម្ភឡើងៗ[56]។ ផ្ទុយទៅវិញ អ្នកក្រនិងជនងាយរងគ្រោះកាន់តែត្រូវបានគេរុញទៅកៀន ហើយមុខរបរចិញ្ចឹមជីវិតត្រូវរងការគំរាមកំហែងមិនចេះចប់។ លើសពីនេះ ជនកម្ពុជាចាប់ផ្ដើមមានអារម្មណ៍ថាត្រូវបានគេផាត់ចេញពីការទទួលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ដែលមានតាមរយៈលំហូរចូលនៃការវិនិយោគរបស់ចិនមកកម្ពុជា។ ទាំងនេះបានមកពីការសង្កេតឃើញថា នៅតាមអាជីវកម្មនិងការដ្ឋានសំណង់របស់ចិន ពួកចិននិយមជួលកម្មករជនជាតិចិនជាងពលរដ្ឋកម្ពុជា[57]។ វត្តមានរបស់ជនជាតិចិនរស់នៅនិងធ្វើការកាន់តែច្រើនឡើងនៅកម្ពុជា បានបណ្ដាលឱ្យជនកម្ពុជាមួយចំនួនមានអារម្មណ៍ថាពួកគេកំពុងស្ថិតក្រោមការគំរាមកំហែង ហើយតាមរយៈនេះអារម្មណ៍ប្រឆាំងចិនចេះតែកើនឡើងដែរ[58]។ ឧទាហរណ៍ត្រង់នេះ ឆ្លុះបញ្ចាំងអំពីភាពខុសគ្នារវាងវណ្ណៈអ្នកមានស្ដុកស្ដម្ភដែលកំពុងលេចឡើងនៅក្នុងសង្គមកម្ពុជា និងភាពខុសគ្នានៅក្នុងឱកាសរបស់ពួកគេសម្រាប់សាមគ្គីភាពសង្គម។

សរុបមកវិញ អនុវិមាត្របរិយាបន្ននេះចាំបាច់ត្រូវការពិនិត្យឱ្យបានដិតដល់ សម្រាប់ជាផ្នែកមួយនៃការវាស់វែងភាពស្និទ្ធស្នាល ដោយសារតែមានស្រទាប់និងមុំច្រើនសម្រាប់ការពិភាក្សាមើលថាតើ ក្រុមមនុស្សផ្សេងៗគ្នាមានលក្ខណៈបរិយាបន្នកម្រិតណាខ្លះនៅកម្ពុជា។ កាលៈទេសៈមានខ្សែបន្ទាត់កំណត់លក្ខខណ្ឌសម្រាប់ការផាត់ចេញរួចជាស្រេច ជាពិសេសនៅក្នុងទិដ្ឋភាពនយោបាយនិងសេដ្ឋកិច្ច ដែលតម្រូវឱ្យមានការវិភាគថែមទៀត ដូចជាការអធ្យាស្រ័យចំពោះសេរីភាពបញ្ចេញមតិ និងចំពោះការផាត់ចេញពីទទួលផលកំណើនសេដ្ឋកិច្ច។ តាមរយៈនេះ បរិយាបន្នសង្គមនឹងក្រសោបនូវលក្ខណៈសម្បត្តិរបស់សង្គមស៊ីវិល សិល្បៈ វប្បធម៌ និងការគាំពារផ្នែកសង្គម។

## វិមាត្រទី៤៖ សន្តិសុខ

| | |
|---|---|
| **សន្តិសុខ** | ស្ថានភាពមួយដែលក្នុងនោះអ្នកណាម្នាក់មានអារម្មណ៍ថាមានសុវត្ថិភាព ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ |

[55] Ibid.

[56] Baldwin, C., & Marshall, A. (2019). Khmer Riche: How Relatives and allies of Cambodia's leader amassed wealth overseas. Retrieved 13 November 2021, from https://www.reuters.com/investigates/special-report/cambodia-hunsen-wealth/

[57] How Chinese money is changing Cambodia | DW | 22.08.2019. (2022). Retrieved 16 January 2022, from https://www.dw.com/en/how-chinese-money-is-changing-cambodia/a-50130240

[58] Wright, G. (2018). Anti-Chinese Sentiment on the Rise in Cambodia. Retrieved 13 November 2021, from https://thediplomat.com/2018/11/anti-chinese-sentiment-on-the-rise-in-cambodia/

| | |
|---|---|
| សន្តិសុខមនុស្ស | សំដៅលើសុវត្ថិភាព និងការពេញចិត្តពេញថ្លើមជាមួយសេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស មានអាហារ ការចិញ្ចឹមជីវិតដោយសុខស្រួល និងការរួចផុតពីការធ្វើទុកបុកម្នេញ។ |
| ការយល់ឃើញអំពីការគំរាមកំហែងផ្នែកសង្គម | សំដៅលើការភ័យខ្លាចប្រចាំថ្ងៃតាមរយៈទំនាក់ទំនងរវាងក្រុម និងអំពើហិង្សា។ |

សន្តិសុខ សំដៅលើស្ថានភាពមួយដែលក្នុងនោះអ្នកណាម្នាក់មានអារម្មណ៍ថាមានសុវត្ថិភាព ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ វាផ្តុំឡើងដោយអនុវិមាត្រចំនួនពីរដែលផ្តោតទៅលើ ***សន្តិសុខមនុស្ស*** និង ***ការយល់ឃើញអំពីការគំរាមកំហែងផ្នែកសង្គម***។

សន្តិសុខមនុស្ស ជាវិមាត្រពាក់ព័ន្ធសំខាន់មួយដែលត្រូវសិក្សាមើលនៅក្នុងបរិបទកម្ពុជា ជាពិសេសនៅក្នុងអំឡុងពេល និងបន្ទាប់ពីមានការផ្ទុះជំងឺរាតត្បាតកន្លងមក។ វិមាត្រមួយនេះ ឆ្លុះបញ្ចាំងពីសុវត្ថិភាព និងការពេញចិត្តពេញថ្លើមជាមួយនឹងសេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស មានអាហារ, ការចិញ្ចឹមជីវិតដោយសុខស្រួល និងការរួចផុតពីការធ្វើទុកបុកម្នេញ។ ជំងឺកូវីដ-១៩ បានទម្លាយ និងបន្លឺឱ្យកាន់តែខ្ទរខ្ទារនូវបញ្ហាសង្គមនានាដែលមានស្រាប់នៅក្នុងប្រទេស។ សម្រាប់ពលករចំណាកស្រុក និងពលករក្រៅប្រព័ន្ធផ្លូវការ តម្រូវការជាមូលដ្ឋានសម្រាប់ជីវភាពរបស់ពួកគេត្រូវបានបំផ្លាញ ដោយសារវិធានការរឹតត្បិតក្នុងអំឡុងពេលមានជំងឺរាតត្បាត។ គុណភាពសេវាសុខាភិបាលនៅមានកម្រិតសម្រាប់ក្រុមប្រជាជនងាយរងគ្រោះ ដូចជាក្រុមជនជាតិដើមភាគតិច ពលករក្រៅប្រព័ន្ធ និងអ្នកឯទៀតដែលរស់នៅតំបន់ចុងកាត់មាត់ញក តាំងតែពីមិនទាន់មានជំងឺកូវីដរាតត្បាតម្ល៉េះ។ វិសមភាពនៅក្នុងលទ្ធភាពទទួលបានតម្រូវការចាំបាច់របស់មនុស្ស នឹងជះឥទ្ធិពលទៅលើគម្លាតក្នុងសាមគ្គីភាពសង្គម។

ការយល់ឃើញអំពីការគំរាមកំហែងផ្នែកសង្គម សំដៅលើការភ័យខ្លាចប្រចាំថ្ងៃតាមរយៈទំនាក់ទំនងរវាងក្រុម និងអំពើហិង្សា។ តាមសេចក្តីរាយការណ៍មួយចំនួន នៅក្នុងឆ្នាំ២០២០ ករណីឧក្រិដ្ឋកម្មអំពើហិង្សា – មានឃាតកម្មអត្តឃាត អំពើហិង្សាប្រដាប់អាវុធ – មានចំនួនកើនឡើងច្រើន ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុ បញ្ហាផ្លូវចិត្តដែលគ្មានការអើពើដោះស្រាយ និងការសេពគប់គ្រឿងញៀន[59]។ តាមការលើកឡើងរបស់អង្គការយូអិនឌីភី ក្រៅពីករណីឧក្រិដ្ឋកម្ម វិមាត្រស្តីពីការគំរាមកំហែងសង្គមជាខ្នាតវាស់វែងវិសាលភាពដែលបុគ្គលមានសម្រាប់គិតគូរមើលអំពីបែបផែនរស់នៅនៃក្រុមរបស់ខ្លួន ដែលរងការរើសអើងនិងការគំរាមកំហែងពីក្រុមដទៃ[60]។ ចំណុចនេះមានចំណងទាក់ទងផ្ទាល់ទៅនឹងបរិបទកម្ពុជា ដែលធ្លាប់មានប្រវត្តិស្ថិតក្រោមការកាន់កាប់របស់ជនចូលមកតាំងទីលំនៅជាជនជាតិចិន ថៃ វៀតណាម បារាំង និងអាមេរិក។ ការប្រកាន់ជំហរយើងប្រឆាំងអ្នក អាចនាំមកនូវផលវិបាកទាំងសងខាង និងគ្មានប្រយោជន៍ដល់សាមគ្គីភាពសង្គមទេ។

ការប្រើប្រាស់អារម្មណ៍ប្រឆាំងវៀតណាមជាឧទាហរណ៍មួយច្បាស់ក្រឡែត។ របាយការណ៍ជាច្រើនបានលើកឡើងពីការរើសអើងចំពោះជនជាតិវៀតណាម រហូតដល់មានការទាមទារឱ្យបណ្តេញចេញពីកម្ពុជាទៀតផង[61]។ សម្តីលើកឡើងដដែលៗអំពីការឈ្លានពានរបស់វៀតណាមបន្ទាប់ពីការផ្តួលរលំរបបខ្មែរក្រហម ត្រូវបានចាត់ទុកថាជាដើមចមនាំឱ្យមានការបង្កើតជានិទានកថាអំពីការគាប់សង្កត់ប្រជាជនកម្ពុជា ។ ត្រង់នេះគឺជាគ្រឿងផ្សំនៃការឃ្នើសចិត្តក្នុងសង្គម និងការយល់ឃើញខុសឆ្គងមួយចំនួន។ ជាងនេះទៅទៀត ក្នុងពេលថ្មីៗនេះ គេសង្កេតឃើញថាមានក្តីកង្វល់រួមច្រើននៅក្នុងចំណោមពលរដ្ឋកម្ពុជា អំពីការហូរចូលយ៉ាងគំហុករបស់ជនជាតិចិន។ ការខឹងសម្បារមានប្រភពចេញ

[59] Lay, S., & Phoung, V. (2021). Violent Crimes Increasing in Cambodia. Cambodianess. Retrieved from https://cambodianess.com/article/violent-crimes-increasing-in-cambodia

[60] UNDP (2020). Strengthening Social Cohesion: Conceptual Framing and Programming Implications, UNDP.

[61] Blomberg, M. (2021). 'Please show mercy': Evicted by Cambodia, ethnic Vietnamese stuck at watery border. Retrieved 19 November 2021, from https://www.reuters.com/article/us-cambodia-vietnam-evictions-idUSKCN2E75RA

ពីការគិតឃើញថា អធិបតេយ្យភាពរបស់កម្ពុជាកំពុងរងការគំរាមកំហែង ថ្វីដ្បិតតែមានការវិនិយោគគម្រោងធំៗរបស់ចិននៅក្នុងព្រះរាជាណាចក្រក៏ដោយ[62]។

ការគិតឃើញថាមានការគំរាមកំហែងផ្នែកសង្គម បានក្លាយជាបញ្ហាកាន់តែធំសម្រាប់បណ្ដាសហគមន៍ជនជាតិដើមភាគតិច។ សហគមន៍ទាំងនេះបន្តរាយការណ៍ឱ្យដឹងអំពីការបាត់បង់ដីធ្លីកាន់តែច្រើនឡើងៗដោយសារការកាប់ព្រៃឈើ និងការធ្វើសម្បទានដីធ្លី ប៉ុន្តែជាមួយគ្នានោះក៏មានរបាយការណ៍អំពីការទាមទារដីបានមកវិញខ្លះដែរ[63]។ ក្នុងមុខងារជាអនុសូចនាករមួយ ការគិតឃើញថាមានការគំរាមកំហែងផ្នែកសង្គមចាំបាច់ត្រូវសម្របទៅនឹងការយល់ឃើញអំពីបណ្ដាក្រុមដែលត្រូវធ្វើការវាស់វែងដែរ។ ឧទាហរណ៍ ការយល់ឃើញក្នុងចំណោមជនកម្ពុជាអំពីការគំរាមកំហែង ផ្ទុយគ្នានឹងការយល់ឃើញអំពីការគំរាមកំហែងក្នុងចំណោមជនជាតិចិននៅកម្ពុជា។ បន្ថែមលើការធ្វើអនុចំណាត់ថ្នាក់ នៅមានការធ្វើចំណាត់ថ្នាក់បីដែលអាចយកមកប្រើ គឺ *ផ្នត់គំនិតអវិជ្ជមាន ការក្រែងរអាគ្នាទៅវិញទៅមក និងគម្លាតសង្គម*។

ក្នុងការពិចារណាអំពីគំរាមសង្គម យកល្អគួរតែពិនិត្យមើលទៅលើវិមាត្របីរួមគ្នា ព្រោះថា ក្នុងការប្រាស្រ័យទាក់ទងជាមួយក្រុមផ្សេងក្នុងសង្គម មានដូចជាយេនឌ័រ ក្រុមជាតិសាសន៍ ឬវណ្ណៈសង្គម គេត្រូវដឹងអំពីភាពមិនជ្រះស្រឡះនៅក្នុងបរិបទកម្ពុជា មិនដូចនៅក្នុងការឱ្យនិយមន័យកន្លងមកទេ។

យូអិនឌីភី បានពន្យល់ពាក្យ ផ្នត់គំនិតអវិជ្ជមាន ថាជា “វង្វាស់នូវវិសាលភាពដែលក្នុងនោះបុគ្គលនានាយល់ដូចម្ដេចអំពីសមាជិកនៅក្នុងក្រុមបដិបក្ស ឧទាហរណ៍ ថាតើ ពួកគេជាមនុស្សគឃ្លើន គួរទុកចិត្តបាន មិនខិតខំធ្វើការ មិនស្អាត ឬ មិនគួរឱ្យរាប់អាន” ឬយ៉ាងណា។ ការក្រែងរអាគ្នាទៅវិញទៅមកសំដៅលើវិសាលភាពនៃអារម្មណ៍អវិជ្ជមានដែលបុគ្គលមានចំពោះក្រុមបដិបក្ស។ គម្លាតសង្គម គឺជាវិធីវាស់វែងការទទួលយកនូវទំនាក់ទំនងសង្គមផ្សេងៗគ្នាជាមួយសមាជិកនៃក្រុមបដិបក្ស[64]។

ដើម្បីទទួលបានការយល់ដឹងស៊ីជម្រៅពីនិយមន័យទាំងនេះ ចាំបាច់ត្រូវមានសកម្មភាពរួមឱ្យចេញជាផ្កាផ្លែ។ ឧទាហរណ៍ ផ្នត់គំនិតអវិជ្ជមាន ចំពោះជនអន្តោប្រវេសន៍មកពីវៀតណាមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា។ ផ្នត់គំនិតអវិជ្ជមាននេះដែរអាចមានសភាពខុសគ្នាស្រឡះចំពោះជនកម្ពុជាដែលមានសែស្រឡាយចិន។ យើងអាចឱ្យនិយមន័យពាក្យផ្នត់គំនិតលម្អៀងនៅលើក្រដាសបាន ប៉ុន្តែយើងក៏ត្រូវពិចារណាផងដែរនូវបរិបទនៃការអនុវត្តរបស់វា និងថាតើវានឹងនាំទៅរកអ្វីជាលទ្ធផល។ នៅក្នុងការភ័យបារម្ភរវាងក្រុម ផ្នត់គំនិតលម្អៀងអាចស្ដែងឡើងតាមបែបអត្តនោម័ត អាស្រ័យទៅលើការថាតើក្រុមសង្គមនីមួយៗមានអាកប្បកិរិយាបែបណាជាមួយក្រុមបដិបក្ស។ ការរំពឹងទុកអំពីលទ្ធផលនឹងជំរុញឱ្យមានការភ័យបារម្ភកាន់តែខ្លាំង ដែលរួមចំណែកបង្កគម្លាតសង្គម រវាងក្រុមខុសៗគ្នា។

---

[62] South China Morning Post. (2022). Change in Cambodia: Sihanoukville's Chinese influx [Video]. Retrieved from https://www.scmp.com/video/scmp-originals/3021938/change-cambodia-sihanoukvilles-chinese-influx
[63] Mech, D., & Baliga, A. (2021). This is My Land: Kuy Villagers Reclaim Preah Vihear Sugar Plantation. VOD. Retrieved from https://vodenglish.news/this-is-my-land-kuy-villagers-reclaim-preah-vihear-sugar-plantation/
[64] UNDP (2020, pp 19-20). Strengthening Social Cohesion: Conceptual Framing and Programming Implications, UNDP.

## ៤. សង្ខេប

ដូចគ្នានឹងប្រទេសនានានៅក្នុងតំបន់អាស៊ីនេះ កម្ពុជាបានឆ្លងកាត់ការប្រែប្រួលស៊ីជម្រៅផ្នែកសេដ្ឋកិច្ច, វប្បធម៌ និងនយោបាយ នៅក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ បើទោះជាសម្រេចបានវឌ្ឍនភាពនៃអភិវឌ្ឍសេដ្ឋកិច្ចគួរឱ្យស្ញប់ស្ញែងក៏ដោយ ប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះនៅតែមានបញ្ហាប្រឈមក្នុងសង្គមរាប់មិនអស់ អមជាមួយនឹងស្នាមរបួសមិនទាន់ជាសះស្បើយអស់ដែលបន្សល់ទុកដោយអតីតកាលបែបប្រល័យពូជសាសន៍។ នៅក្នុងទិដ្ឋភាពនយោបាយ កម្ពុជាជាប្រទេសមួយដែលសហគមន៍អន្តរជាតិមើលមកលើក្នុងក្រសែភ្នែកមិនល្អ ដោយសារតែរបបគ្រប់គ្រងផ្តាច់ការរបស់មេដឹកនាំមួយរូប ដែលកាន់កាប់អំណាចអស់ពេលជាយូរមកហើយ។ សូចនាករអភិវឌ្ឍន៍មនុស្ស និងផ.ស.ស (ផលិតផលក្នុងស្រុកសរុប) មានកម្រិតខ្ពស់ជាងមុនក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែជាប់លេខរៀងទាបក្នុងសន្ទស្សន៍អំពើពុករលួយ, សន្ទស្សន៍សេរីភាពសារព័ត៌មាន, សន្ទស្សន៍ផ្នែកយុត្តិធម៌ និងនីតិរដ្ឋ នេះគ្រាន់តែលើកឡើងត្រួសៗប៉ុណ្ណោះ។ នៅលើផ្លូវចំណុចប្រសព្វរវាងវឌ្ឍនភាពនិងដំណើរថយក្រោយ កម្ពុជាកំពុងប្រឈមនឹងបញ្ហាច្រើនទៀតក្នុងការរក្សាឯកភាពជាតិ ក្រោយពីឆ្លងកាត់បទពិសោធន៍ជូរចត់ក្នុងអតីតកាលរបស់ខ្លួន។

សាមគ្គីភាពសង្គម អាចជាពាក្យសព្ទថ្មីសម្រាប់កម្ពុជា ប៉ុន្តែគោលគំនិតរបស់វាមិនថ្មីទេ។ គេអាចសង្កេតឃើញគោលគំនិតនេះតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់សន្តិភាព និងឯកភាព កន្លងមក បើទោះជាកិច្ចខិតខំទាំងនោះមានបង្កប់ទៅដោយចេតនានយោបាយក៏ដោយ។ មិនខុសពីប្រជាជាតិអាស៊ីដទៃទៀតទេ កម្ពុជាជាប្រទេសដែលគ្រប់គ្រងតាមប្រព័ន្ធបែបគ្រួសារនិយម បែបសហគមន៍និយម និងបែបចៅហ្វាយនាយ-កូនចៅនិយម។ គុណតម្លៃទាំងនេះនឹងដើរតួសំខាន់នៅក្នុងការកំណត់ចរិតលក្ខណៈរបស់សាមគ្គីភាពសង្គមនៅកម្ពុជា។ វិមាត្រទាំងឡាយនៃសាមគ្គីភាពសង្គមដែលលើកឡើងដោយយូអិនឌីភី អាចយកមកអនុវត្តនៅក្នុងបរិបទកម្ពុជា យ៉ាងណាក៏ដោយ វិមាត្រខ្លះចាំបាច់ត្រូវកែសម្រួលឬច្របាច់បញ្ចូលគ្នាជាមុនសិន។ ជាអនុសាសន៍ យូអិនឌីភីគួរតែធ្វើការពិចារណាលើវិមាត្រមួយចំនួន ដែលត្រូវបានស្នើឡើងដោយគម្រោងតួយ៉ាងគម្រោង Social Cohesion Radar ដែលបានសិក្សាទៅលើប្រទេសអាស៊ីជាច្រើន រួមទាំងកម្ពុជាផង។ វិមាត្រដែលបានស្នើឡើងទាំងនោះមានៈ

**តារាងទី២៖ សង្ខេបវិមាត្រសាមគ្គីភាពសង្គម**

<table>
<tr><td colspan="2">វិមាត្រទី១៖ ការជឿទុកចិត្ត<br>លក្ខណៈសម្បត្តិ/ជំនឿផ្ទាល់ខ្លួនទៅលើមនុស្សណាម្នាក់ ក្រុម ឬស្ថាប័នណាមួយ ឬជាការរំពឹងទុកអំពីការដោះដូរ ឬការធ្វើបដិកាទៅវិញទៅមក ដោយសមហេតុសមផល។</td></tr>
<tr><td>ការជឿទុកចិត្តលើសាសនា</td><td>ជាការទុកចិត្តផ្អែកលើជំនឿលើស្ថាប័ន, ថ្នាក់ដឹកនាំ និងទម្លាប់អនុវត្តរបស់ផ្នែកសាសនា។</td></tr>
<tr><td>ការជឿទុកចិត្តលើស្ថាប័ន</td><td>ការទុកចិត្តលើប្រព័ន្ធអភិបាលកិច្ចនយោបាយ។</td></tr>
<tr><td>ការជឿទុកចិត្តលើសហគមន៍</td><td>ជាទំនាក់ទំនងតាមខ្សែដេក និង ការធ្វើអន្តរកម្ម (ឬការប្រាស្រ័យទាក់ទង) ក្នុងចំណោមពលរដ្ឋ។</td></tr>
<tr><td>ការជឿទុកចិត្ត<br>លើថ្នាក់ដឹកនាំ</td><td>ការទុកចិត្តលើបុគ្គលនៅក្នុងជួរដឹកនាំនយោបាយ។</td></tr>
<tr><td colspan="2">វិមាត្រទី ២៖ ភាពចូលចំណោម<br>គោលគំនិតស្តីពីភាពចងក្រងគ្នាជាក្រុមជាពួក ផ្អែកលើអត្តសញ្ញាណវប្បធម៌ និងជាតិសាសន៍។</td></tr>
</table>

<table>
<tr><td>អត្តសញ្ញាណ</td><td>ជាលក្ខណៈសម្បត្តិដែលបុគ្គល ឬ ក្រុមមនុស្សមានជាគ្រឿងសម្គាល់ផ្ទាល់ខ្លួន។</td></tr>
<tr><td>ភាពអធ្យាស្រ័យ</td><td>ការទទួលយកនូវពិពិធភាព។</td></tr>
<tr><td colspan="2">វិមាត្រទី ៣៖ បរិយាបន្ន<br>សំដៅលើវិសាលភាពដែលមនុស្សម្នាក់មានសម្រាប់ការចូលរួមនានានៅក្នុងសង្គម ដោយគ្មានការភ័យខ្លាចចំពោះការរើសអើង ការផាត់ចេញ ឬការបង្ខំ ណាមួយ។</td></tr>
<tr><td>បរិយាបន្នសេដ្ឋកិច្ច</td><td>តំណាងដោយសូចនាករស្តីពីការចូលរួមផ្នែកសេដ្ឋកិច្ច និងការធ្វើសេចក្តីសម្រេចនានា។</td></tr>
<tr><td>បរិយាបន្ននយោបាយ</td><td>តំណាងដោយការចូលរួមស្មើភាពនិងយ៉ាងសកម្មរបស់ប្រជាជននៅក្នុងវិស័យនយោបាយ។</td></tr>
<tr><td>បរិយាបន្នសង្គម</td><td>តំណាងដោយដំណើរការកែលម្អឱ្យប្រសើរនូវលក្ខខណ្ឌនានា សម្រាប់ការចូលរួមរបស់បុគ្គលឬក្រុម នៅក្នុងសង្គម។</td></tr>
<tr><td colspan="2">វិមាត្រទី៤៖ សន្តិសុខ<br>ស្ថានភាពមួយដែលក្នុងនោះអ្នកណាម្នាក់មានអារម្មណ៍ថាមានសុវត្ថិភាព ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។</td></tr>
<tr><td>សន្តិសុខមនុស្ស</td><td>សំដៅលើសុវត្ថិភាព និងការពេញចិត្តពេញថ្លើមជាមួយសេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស មានអាហារ ការចិញ្ចឹមជីវិតដោយសុខស្រួល និងការរួចផុតពីការធ្វើទុកបុកម្នេញ។</td></tr>
<tr><td>ការយល់ឃើញអំពីការគំរាមកំហែងផ្នែកសង្គម</td><td>សំដៅលើការភ័យខ្លាចប្រចាំថ្ងៃតាមរយៈទំនាក់ទំនងរវាងក្រុម និងអំពើហិង្សា។</td></tr>
</table>

**Annex: Social Cohesion Key terms**

| No. | English Terms | Khmer | Note |
|---|---|---|---|
| 1. | Social Cohesion | សាមគ្គីភាពសង្គម | |
| 2. | Trust | ការជឿទុកចិត្ត | |
| 3. | Belonging | ភាពចូលចំណោម | |
| 4. | Inclusion | ភាពបរិយាប័ន្ន | |
| 5. | Dimension | វិមាត្រ | |
| 6. | Contemporary | បច្ចុប្បន្ន | |
| 7. | Concept | ការយល់ឃើញ | |
| 8. | LGBTQI+ | ក្រុមអ្នកស្រលាញ់ភេទដូចគ្នា (LGBTQI+) | |
| 9. | Means-end approach | អភិក្រមមធ្យោបាយ-គោលដៅ ឬ គោលវិធីមធ្យោបាយ-គោលដៅ | |
| 10. | Connectedness | ភាពភ្ជាប់គ្នា | |
| 11. | Cohesion | ភាពស្អិទ្ធស្អាល | |
| 12. | Sense of togetherness | អារម្មណ៍អំពីភាពចុះសម្រុង | |